**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការលុបចោលអាពាហ៍ពិពាហ៍

ស្រាវជ្រាវ ពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៨ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៨

ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ **កញ្ញា. ឆាយ ធីតា**

**កញ្ញា. ខិន្ន ម៉ីជូ**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ស្រី វណ្ណធី**

ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា៖ ២០១៤

ឆ្នាំសរសេរសារណា៖ ២០១៨

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **ក.ឆាយ ធីតា** និង **ក.វិន្ទ ម៉ីជូ** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៤-២០១៨។ ក្នុងនាមយើងខ្ញុំ ជាយុវជនជំនាន់ក្រោយ ដែលជាទំពាំងស្នងឫស្សី និងជាសសរទ្រូងនៃប្រទេសជាតិ យើងខ្ញុំបានស្រាវជ្រាវ និងសរសេរជាសារណា ដើម្បីការពារក្នុងការបញ្ចប់ឆ្នាំសិក្សា ក្រោមប្រធានបទស្តីពី "**ការលុបចោលអាពាហ៍ពិពាហ៍**" ។

**យើងខ្ញុំសូមសម្តែងនូវកត្តញ្ញូតាធម៌ និងអំណរអរគុណដ៏ខ្ពង់ខ្ពស់បំផុត ជូនចំពោះ៖**

- លោកឪពុក **ខាន់ សុខា** និងអ្នកម្តាយ **នួន ហុងសេង**
- លោកឪពុក **ជុន ទេវិន្ទ** អ្នកម្តាយ **លី ហៀកមួយ** និងអ្នកម្តាយធំ **លី ស៊ីវអេង**

សូមអរគុណដល់ លោកអ្នកមានគុណ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ ណែនាំផ្តល់ដំបូន្មាន ព្រមទាំងផ្គត់ផ្គង់ជា ថវិកា សម្ភារៈប្រើប្រាស់ក្នុងការសិក្សា ផ្តល់ឲ្យគ្រប់យ៉ាងនូវកម្លាំងកាយ កម្លាំងចិត្តទាំង ផ្នែកបញ្ញា និងស្មារតី លើកទឹកចិត្តក្នុងការខិតខំសិក្សារៀនសូត្រ ក្រេបយកនូវចំណេះដឹង តាំងតែពីតូចក្រូចឆ្មារ រហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។ គុណូបការៈ និងព្រហ្មវិហាធម៌របស់លោកអ្នកមានគុណ ចំពោះយើងខ្ញុំពិតជាមានទំហំធំធេងរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ ទាំងនេះហើយដែល ធ្វើឲ្យកូនមិនអាចបំភ្លេចបាន ហើយគុណធម៌ និងព្រហ្មវិហាធម៌ទាំងនោះនឹងស្ថិតនៅក្នុងចិត្តកូនជានិច្ចដរាប។

យើងខ្ញុំសូមថ្លែងអំណរអគុណដល់ **ឯកឧត្តមសាកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរងនិងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីសមត្ថភាព ក្នុងផ្តល់និងផ្ទេរនូវចំណេះដឹង បទពិសោទធន៍ ឯកសារ សិក្សាស្រាវជ្រាវ ដែលជាប្រទីបបំភ្លឺផ្លូវដល់យើងខ្ញុំក្នុងការសិក្សារៀនសូត្ររហូតមក។

សូមថ្លែងអំណរអគុណយ៉ាងជ្រាលជ្រៅដល់ **លោកស្រីសាស្ត្រាចារ្យ ស្រី វណ្ណធី** ដែលលោកមិនត្រឹមតែបានបង្រៀន ផ្តល់នូវចំណេះដឹងនោះទេ លោកថែមទាំងជា សាស្ត្រាចារ្យ

ណែនាំ និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្ដល់ការប្រឹក្សា និងអនុសាសន៍ល្អៗ ដែលធ្វើឲ្យកិច្ចដំណើរការនៃការស្រាវជ្រាវ និងចងក្រងនូវឯកសារសារណានេះប្រកបដោយ លទ្ធផលល្អនេះ។

សូមថ្លែងអំណរគុណជូនចំពោះ លោកតា លោកយាយ អ៊ំប្រុស អ៊ំស្រី លោកពូ អ្នកមីង បងប្អូន មិត្តភក្តិ និងសិស្សច្បង ទាំងអស់ ដែលបានផ្ដល់ជាគំនិត និងកម្លាំងចិត្តដល់ យើងខ្ញុំក្នុងការសរសេរសារណានេះ។

ជាអវសាន យើងខ្ញុំសូមគោរពជូនពរ និងលើកហត្ថប្រូងស្នូងដល់គុណ ព្រះរតនត្រៃយ៍ គុណកែវទាំងបី អស់វត្ថុស័ក្តិសិទ្ធិក្នុងលោក ជួយតាមថែរក្សា **លោកឪពុក អ្នកម្ដាយ ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រទ្ធបុរសរង និងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ** ឲ្យជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងជួបប្រកប តែសុខស្ងួស្តីគ្រប់ប្រការកុំបីឃ្លាតកាយទៅជាបការៈដទៃឡើយ៕

# អារម្ភកថា

តាមរយៈការសិក្សាអស់ពេល ៤ឆ្នាំ ក្នុងមុខវិជ្ជាផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំទាំងពីរនាក់បានសិក្សាស្រាវជ្រាវ ឯកសារផ្សេងៗជាច្រើន ពិសេសក្នុងផ្នែកនីតិរដ្ឋប្បវេណី ដែលជាហេតុបណ្តាលឲ្យ យើងខ្ញុំបាន យល់ឃើញនូវចំណុចខ្វះខាតដែលពលរដ្ឋខ្មែរភាគច្រើន ដោយពលរដ្ឋខ្មែរមួយចំនួនក៏ត្រូវបាន រៀបអាពាហ៍ពិពាហ៍ជាមួយនិងពលរដ្ឋខ្មែរ ហើយមួយជំនួនទៀតរៀបអាពាហ៍ពិពាហ៍ ជាមួយនឹង ជនបរទេសដោយក្នុងនោះផងដែរឪពុកម្តាយ ឬសាមីជនខ្លួនឯងមួយចំនួនបានគិត អំពីផលប្រយោជន៍ដែលបានមកពីការរៀបអាពាហ៍ពិពាហ៍ នោះជាធំ។

ដើម្បីចូលរួមចំណែកក្នុងការជួយសង្គម យើងខ្ញុំជាសិស្សនិស្សិត ក៏បានស្រាវជ្រាវសារណាមួយដែលមានប្រធានបទស្តីពី "**ការលុបចោលអាពាហ៍ពិពាហ៍**" មកធ្វើជាកម្មវត្ថុក្នុងការស្រាជ្រាវដើម្បីបញ្ចប់ឆ្នាំសិក្សានេះ។ ដើម្បីជួយឲ្យប្រជាជនខ្មែរបានយល់ដឹងកាន់តែច្បាស់ អំពីសិទ្ធិរបស់ខ្លួនក្នុងការ លុបចោលនូវអាពាហ៍ពិពាហ៍ ដែលផ្ទុយច្បាប់ឬ ដោយការបង្ខិតបង្ខំ ការបោកប្រាស់ផ្សេងៗតាមគ្រប់រូបភាព។ ក្នុងសារណាមួយច្បាប់នេះយើងខ្ញុំទាំងពីរនាក់ បានស្រាវជ្រាវ និងដកស្រង់ចេញពីបណ្តាឯកសារមួយចំនួនទាំងក្នុងបណ្ណាល័យ ក៏ដូចជាតាមប្រភេទឯកសារផ្សេងៗដែលអាចជួយជាគំនិត និងប្រាប់ពីចំណុចសំខាន់ដែលទាក់ទងនឹងប្រធានបទនេះ។ ជាពិសេសនាងខ្ញុំក៏បានទទួលការណែនាំយ៉ាងយកចិត្តទុកដាក់ពីសំណាក់លោកស្រីសាស្ត្រាចារ្យ ដែលលោកស្រីជាអ្នករៀបចំ ដឹកនាំក្នុងការស្វែងរកនូវឯកសារ ក៏ដូចជាការផ្តល់ជាគំនិតយោបល់ ចំពោះប្រធានបទនេះ។

យើងខ្ញុំជឿជាក់ថា អត្ថបទស្រាវជ្រាវនេះជាឯកសារមួយដ៏សំខាន់ ដែលវាអាចជាជំនួយដល់មិត្តអ្នកអាន ក្នុងការយល់ដឹងបន្ថែមពីចំណុចមួយចំនួនដែលទាក់ទង នឹងផ្នែករដ្ឋប្បវេណីជាពិសេសគឺ ការលុបចោលអាពាហ៍ពិពាហ៍។ ប៉ុន្តែក្រោយពីធ្វើកិច្ចការនេះរួចយើងខ្ញុំក៏យល់បានថែមមួយកំរិតទៀត ដែលអាចជួយឲ្យខ្ញុំបានដើរទៅតាមអ្វីដែលច្បាប់បានចង្អុលបង្ហាញ និងបានស្វែងយល់ពីវាផងដែរ។

ជាទីបញ្ចប់យើងខ្ញុំក៏សូមអភ័យទោសរាល់កំហុសខុសឆ្គងដែលបានកើត មានឡើងក្នុងការសរសេរសារណា មួយក្បាលនេះឡើងរមែងតែងតែមាន កំហុសឆ្គងដោយប្រការណាមួយជាក់ជាពុំខាន។

# មាតិកា

ទំព័រ


សេចក្តីផ្តើម ........ ១

១៖ លំនាំបញ្ហា ........ ១

២៖ ចំណោទបញ្ហា ........ ៤

៣៖ គោលបំណង ........ ៤

៤៖ ទំហំកំណត់ និងវិសាលភាព ........ ៤

៥៖ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៥

៦៖ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៥

ជំពូកទី១៖ ការលុបចោលអាពាហ៍ពិពាហ៍

សញ្ញាណទូទៅនៃការលុបចោលអាពាហ៍ពិពាហ៍៖ ........ ៦

ផ្នែកទី១. មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ... ៧

១.១. មិនគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ ........ ៧

១.២. អាពាហ៍ពិពាហ៍រវាងញាតិលោហិត ........ ៨

១.៣. អាពាហ៍ពិពាហ៍រវាងញាតិពន្ធ ........ ៨

១.៤. ទ្វេពន្ធភាព ........ ៩

១.៥. អាពាហ៍ពិពាហ៍អំឡុងពេលហាមឃាត់ ........ ៩

១.៦. អាពាហ៍ពិពាហ៍ដោយការឆបោក ឬគំរាម ........ ១០

ផ្នែកទី២. មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ១០

២.១. អាពាហ៍ពិពាហ៍ដោយគ្មានឆន្ទៈ ឬដោយបង្ខិតបង្ខំ ........ ១០

២.២. អាពាហ៍ពិពាហ៍ដោយគ្មាក់ខារើសគូស្រករ ........ ១១

២.៣. អាពាហ៍ពិពាហ៍ដោយការឆបោក ........ ១២

ផ្នែកទី៣. អាជ្ញាយុកាលនៃការប្តឹងលុបចោលអាពាហ៍ពិពាហ៍ ........ ១២

៣.១. អាជ្ញាយុកាលដែលកំណត់ដោយច្បាប់ ........ ១២

៣.២. អាជ្ញាយុកាលដែលកើតឡើងដោយការបង្ហាញឆន្ទៈ ........ ១៣

៣.២.១. មូលហេតុស្ថិតក្នុងអំឡុងពេលហាមឃាត់ ........ ១៣

៣.២.២. មូលហេតុឆបោក ឬគំរាម ........ ១៣

ផ្នែកទី៤. អ្នកមានសិទ្ធិទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ ........ ១៣

៤.១. ភាគីដែលរៀបអាពាហ៍ពិពាហ៍ ........ ១៤

៤.២. ញាតិសណ្តានរបស់ភាគី ........ ១៤

៤.៣. តំណាងអយ្យការ ........ ១៥

៤.៤. ទ្វេពន្ធភាព ........ ១៥

ជំពូកទី២៖ នីតិវិធីនៃការលុបចោលអាពាហ៍ពិពាហ៍

ផ្នែកទី១៖ សមត្ថកិច្ចតុលាការ ........ ១៦

ផ្នែកទី២៖ បណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ ........ ១៧

២.១. ការដាក់ពាក្យបណ្តឹង ........ ១៧

២.១.១. របៀបដាក់ពាក្យបណ្តឹង ........ ១៧

២.១.២. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង ........ ១៧

ផ្នែកទី៣៖ ការបង់ពន្ធប្រាក់ប្រដាប់ក្តី ........ ១៨

៣.១. ប្រភេទប្រាក់ប្រដាប់ក្តី ........ ១៩

៣.២. បន្ទុកនៃប្រាក់ប្រដាប់ក្តី ........................................................................ ១៩

ផ្នែកទី៤៖ ការចាត់ចែងពាក្យបណ្តឹង ........................................................................ ២០

៤.១. ការទទួលពាក្យបណ្តឹង ........................................................................ ២០

៤.២. ការពិនិត្យពាក្យបណ្តឹង ........................................................................ ២១

៤.៣. ការបញ្ជូនពាក្យបណ្តឹង ........................................................................ ២១

៤.៤. ការកំណត់កាលបរិច្ឆេទត្រៀមសម្រាប់ទាញហេតុផលផ្ទាល់មាត់ ........................ ២៤

ផ្នែកទី៥៖ នីតិវិធីនៃការត្រៀម និងទាញហេតុផលផ្ទាល់មាត់ ........................................ ២៤

៥.១. នីតិវិធីត្រៀមសម្រាប់ទាញហេតុផលផ្ទាល់មាត់ ........................................ ២៥

៥.២. នីតិវិធីទាញហេតុផលផ្ទាល់មាត់ ........................................................ ២៥

៥.២.១. ការជម្រះក្តីក្នុងការទាញហេតុផលផ្ទាល់មាត់ ........................................ ២៦

៥.២.២. ការបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ ................................................ ២៧

ផ្នែកទី៦៖ សេចក្តីសម្រេចលើបណ្តឹង ........................................................................ ២៨

៦.១. សាលក្រមចំពោះមុខ ........................................................................ ២៨

៦.២. បណ្តឹងឧបាស្រ័យ ........................................................................ ២៨

ជំពូកទី៣៖ អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍

ផ្នែកទី១៖ អានុភាពចំពោះសំណងការខូចខាត ................................................ ៣០

ផ្នែកទី២៖ អានុភាពចំពោះបុគ្គល ........................................................................ ៣១

២.១. ចំពោះសាមីជន ........................................................................ ៣១

២.២. ចំពោះបុត្តភាព ........................................................................ ៣១

ផ្នែកទី៣៖ អានុភាពចំពោះទ្រព្យសម្បត្តិ ........................................................ ៣៣

៣.១. ចំពោះសកម្មទ្រព្យ ....................................................................................................... ៣៣
៣.១.១. ប្រព័ន្ធទ្រព្យសម្បត្តិតាមវិធាននៃកិច្ចសន្យា ................................................................ ៣៤
៣.១.២. ប្រព័ន្ធទ្រព្យសម្បត្តិកំណត់តាមច្បាប់ ........................................................................... ៣៤
៣.១.២.១. ទ្រព្យសម្បត្តិដោយឡែក ............................................................................................ ៣៤
៣.១.២.២. ទ្រព្យសម្បត្តិរួម .............................................................................................................. ៣៥
៣.២. ចំពោះអកម្មទ្រព្យ ....................................................................................................... ៣៥
៣.២.១. អកម្មទ្រព្យដោយឡែក .................................................................................................. ៣៦
៣.២.២. អកម្មទ្រព្យរួម ............................................................................................................... ៣៦
ផ្នែកទី៤៖ បញ្ហាប្រឈមដែលកើតមាន ........................................................................................ ៣៦
៤.១. ផុតអាជ្ញាយុកាលនៃបណ្ដឹង ......................................................................................... ៣៦
៤.២. មរណភាពភាគី ............................................................................................................ ៣៧
៤.៣. មិនមានភាពទូលំទូលាយក្នុងការអនុវត្តន៍ ................................................................ ៣៧
៤.៤. ការទទួលខុសត្រូវព្រហ្មទណ្ឌ........................................................................................ ៣៨
សេចក្ដីសន្និដ្ឋាន ............................................................................................................... ៤០
អនុសាសន៍........................................................................................................................ ៤១
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

## ១៖ លំនាំបញ្ហា

នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ការគោរពនិងប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន ទៅនឹងប្រពៃណីទំនៀមទម្លាប់ក្នុងការប្រារព្ធ នូវពិធីផ្សេងៗ ដោយក្នុងនោះផងដែរក៏មាន ពិធីរៀបអាពាហ៍ពិពាហ៍ ដែលយើង គ្រប់គ្នានិយមហៅថា ការរៀបមង្គលការ។ ពីបុរាណកាលមក មុននឹងឈានដល់ការរៀបអាពាហ៍ពិពាហ៍ គឺយើងមានពិធីរៀបចំជាច្រើនដំណាក់កាលផ្សេងៗគ្នា។ ក្នុងនោះដែរមាន ដូចជា ពិធីចែចូវចូលស្តីដណ្តឹង ពិធីភ្ជាប់ពាក្យ ឬកំជាប់ពាក្យ ទើបឈានចូលដល់ពិធីរៀបអាពាហ៍ពិពាហ៍ ដោយពិធីទាំងអស់នេះ ធ្វើឡើងផ្សេងៗគ្នា ទៅតាមតំបន់ ឬលទ្ធភាពរបស់គ្រួសារនីមួយៗផង។ ប៉ុន្តែទោះបីជាមានពិធីតាមប្រពៃណី យ៉ាងនេះក្តី ក៏អាពាហ៍ពិពាហ៍នោះ មិនត្រូវបានច្បាប់ចាត់ទុកថាជា អាពាហ៍ពិពាហ៍ដែលត្រឹមត្រូវ តាមច្បាប់កំណត់នោះទេ។

អាពាហ៍ពិពាហ៍ គឺជាទំនាក់ទំនងសង្គម រវាងសមាជិកគ្រួសារ ប្តីនិងប្រពន្ធ កូនៗនិងឪពុកម្តាយ ឬរវាងបណ្តាបុគ្គល ផ្សេងទៀតដែលជា សមាជិកនៃគ្រួសារទាំង សងខាង។ ម្យ៉ាងវិញទៀតយើងក៏អាច និយាយបានថា អាពាហ៍ពិពាហ៍ គឺជាមូលដ្ឋានរបស់គ្រួសារ ពីព្រោះថា បុរសនិងស្ត្រី ដែលបានជ្រើសរើសគ្នាធ្វើជាគូស្វាមីភរិយា សុទ្ធសឹងតែមានគោលបំណងក្នុងការកសាងគ្រួសារសម្រាប់រស់នៅក្នុងសង្គមមួយ ជាមួយគ្រួសារដ៏ពេញលេញ និងមានសុភមង្គលមួយតាមចិត្តប្រាថ្នា។ អាពាហ៍ពិពាហ៍ ក៏ជាចំណង មនោសញ្ចេតនា រវាងបុរសនិងស្ត្រីពីរនាក់ ដោយផ្អែកលើមូលដ្ឋានស្ម័គ្រចិត្ត និងសមភាព ហើយ ត្រូវបានច្បាប់ទទួលស្គាល់ពីគោលបំណងក្នុងការកសាងគ្រួសាររបស់ខ្លួន ដោយការព្រមព្រៀង ប្រកបដោយសុភមង្គលផង។ បើតាមបញ្ញត្តិច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានឲ្យ និយមន័យ អាពាហ៍ពិពាហ៍ ថាជាកិច្ចសន្យាឱឡារិកមួយដែលធ្វើឡើង ដោយបុរស និងស្ត្រីម្នាក់ ដែលប្តេជ្ញាចិត្ត ថាខ្លួន នឹងរួមសមគ្គសង្វាសគ្នា តាមរយៈបញ្ញត្តិច្បាប់ ហើយមិនអាចរំលាយ វិញទៅតាមទំនើងចិត្ត របស់ខ្លួនឡើយ[1]។

ចំណងអាពាហ៍ពិពាហ៍ កើតឡើង ដោយការ ស្ម័គ្រចិត្តរវាងបុរស និងស្ត្រីដោយខ្លួនឯង គឺវាឆ្លុះបញ្ចាំង នូវគោលការណ៍សំដែងឆន្ទៈ ដោយឈរលើទស្សនៈ នៃសេរីភាពស្វ័យសម្រេចលើការរើសគូស្រករ ដោយស្របតាមបញ្ញត្តិច្បាប់ ដោយគ្មានការបង្ខិតបង្ខំពីសំណាក់ បុគ្គលណាម្នាក់ ដូចជា ឪពុកម្តាយ បងប្អូនសាច់ញាតិ។ ចំពោះ អាពាហ៍ពិពាហ៍ ដែលបានបង្កើតឡើងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍និង គ្រួសារឆ្នាំ១៩៨៩ គឺនឹងមិនបាត់បង់សុពលភាពយោងតាម ច្បាប់ថ្មីបច្ចុប្បន្ន

[1]ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ,លេខ៥៦ក្រ,២០ កក្កដា ឆ្នាំ១៩៨៩មាត្រា ៣។

ឡើយ ដោយសន្មតជា មុននូវសុពលភាពនៃអាពាហ៍ពិពាហ៍ដែលត្រូវបានបង្កើតឡើង តាមច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារឆ្នាំ១៩៨៩ [2] ។

រៀបអាពាហ៍ពិពាហ៍ បានលុះត្រាតែ មានភេទផ្ទុយគ្នា ហើយបានដល់នីតិភាព មានន័យថា អាយុ១៨ឆ្នាំយ៉ាងតិច[3]។ ប៉ុន្តែជនដែលមាន អាយុ១៦ឆ្នាំឬ១៧ឆ្នាំ ក៏អាចរៀបអាពាហ៍ពិពាហ៍បានដែរ ដោយសារជននោះទទួលបាន អត្តាធីនភាព[4]។ ម៉្យាងទៀត ប្រសិនបើភាគីដែលមានបំណងចង់រៀប អាពាហ៍ពិពាហ៍ ដោយមានភាគីម្ខាងជាអនីតិជន រៀបអាពាហ៍ពិពាហ៍ នឹងអាចប្រព្រឹត្តទៅបាន ដោយគ្រាន់តែមាន ការអនុញ្ញាតពី ឪពុកម្ដាយឬ អាណាព្យាបាលរបស់អនីតិជននោះ[5]។ ប៉ុន្តែប្រសិនបើឪពុកម្ដាយឬ អាណាព្យាបាលសម្រាប់ អនីតិជននោះបដិសេធមិនយល់ស្របចំពោះអាពាហ៍ពិពាហ៍នោះ សាមីជនមានសិទ្ធិប្ដឹងទៅតុលាការ ដើម្បីច្រានចោលការបដិសេធនោះបាន[6] ហើយតុលាការ នឹងពិនិត្យសម្រេចគាំទ្រ ឬមិនគាំទ្រ ការជំទាស់របស់អ្នកមានសិទ្ធិអំណាចមេបាលើភាគីអនីតិជននោះ ក្រោយពីការស្ដាប់ការបំភ្លឺរបស់អាណាព្យាបាល។

ដោយព្រះរាជាណាចក្រកម្ពុជា បានអនុម័តច្បាប់ឯកពន្ធភាពឆ្នាំ២០០៦ ដោយក្នុងនោះបានកំណត់ថាបុគ្គលដែលមានសហព័ទ្ធហើយ មិនអាចរៀបអាពាហ៍ពិពាហ៍ទៀតបានទេ។ ដូច្នេះការបំពានលក្ខខណ្ឌនេះ នឹងនាំមកឲ្យមានការទាមទារឲ្យលុបចោលស្របតាមលក្ខខណ្ឌ ដែលមានចែងក្នុង មាត្រា៩៤៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ដោយឡែកចំពោះបុគ្គល ដែលបានបាត់ខ្លួនបន្ទាប់ពីបានស្នើសុំតុលាការស្ដីពីការប្រកាសអំពីការបាត់ខ្លួនរួចរាល់ សហព័ទ្ធម្ខាងទៀតនឹងអាចរៀបអាពាហ៍ពិពាហ៍ជាថ្មីម្ដងទៀតជាមួយបុគ្គលម្នាក់ទៀតបាន។

ក្រោយការរំលាយនូវចំណងអាពាហ៍ពិពាហ៍ ជាគោលការណ៍នារីនឹងអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានដោយត្រូវស្ថិតក្នុង វិធវភាព (ភាពជាស្ត្រីមេម៉ាយ) រយៈពេល១២០ថ្ងៃគិតចាប់ពីអាពាហ៍ពិពាហ៍ចាស់ត្រូវបានរំលាយ។

ភាគីនៃអាពាហ៍ពិពាហ៍ ត្រូវតែមិនមែនជាញាតិលោហិតខ្សែផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣ថ្នាក់រាប់ទាំងថ្នាក់ទី៣ផង។

---

[2] ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី,លេខ នស/រកម/១០៩៦/៣០,៩ តុលា ឆ្នាំ១៩៩៦,មាត្រា ៦២។

[3] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១៧។

[4] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ២១។

[5] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ៩៥៨។

[6] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ៩៥៣។

ភាគីនៃអាពាហ៍ពិពាហ៍ ត្រូវតែមិនមែនជាញាតិពន្ធខ្សែផ្ទាល់ និងសាខាញាតិក្នុង៣ថ្នាក់ ប៉ុន្តែចំពោះក្នុងករណី សហព័ទ្ធម្ខាងទៀតនៃអាពាហ៍ពិពាហ៍ទទួលមរណភាព សហព័ទ្ធម្ខាងទៀតអាចរៀបអាពាហ៍ពិពាហ៍ជាមួយ បុគ្គលដែលធ្លាប់ជាសាខាញាតិពន្ធនៅក្នុង៣ថ្នាក់បាន។

បន្ទាប់ពីបានគោរពនូវលក្ខខណ្ឌខាងលើរួចហើយ ភាគីរៀបអាពាហ៍ពិពាហ៍ក៏ត្រូវគោរពទៅតាមនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ដែលមានដូចជា ភាគីនៃអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ជាមួយមន្ត្រីអាត្រានុកូលដ្ឋានខាងលំនៅដ្ឋានរបស់នារី ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅចំពោះមុខមន្ត្រី អត្រានុកូលដ្ឋាន [7] ។ ការចុះសំបុត្រអាពាហ៍ពិពាហ៍នឹងមានអានុភាព បន្ទាប់ពីមានការ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដោយមានសាក្សីគ្រប់ អាយុការពីរនាក់។ ទាំងនេះជាលក្ខខណ្ឌចាំបាច់ក្នុងការនាំឲ្យអាពាហ៍ពិពាហ៍ មានចំណងគតិយុត្តត្រឹមត្រូវតាមផ្លូវ ច្បាប់។

ដោយឡែកពលរដ្ឋខ្មែរដែលរស់នៅបរទេស ក៏អាចរៀបអាពាហ៍ពិពាហ៍រវាងគ្នាបានដូចគ្នា ពលរដ្ឋខ្មែរដែលរស់នៅបរទេស អាចដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយត្រូវជូនដំណឹងជាសាធារណៈ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ចុះបញ្ជីអាពាហ៍ពិពាហ៍ នៅចំពោះមុខឯកអគ្គរាជទូតភារធារីឬ ស្ថានកុងស៊ុល របស់កម្ពុជាប្រចាំប្រទេសនោះ។ ការជូនដំណឹងជាសាធារណៈ ត្រូវបិទនៅបញ្ជរស្ថានទូត ឬស្ថានកុងស៊ុលរបស់កម្ពុជាប្រចាំនៅប្រទេសនោះ [8] ។ ពលរដ្ឋកម្ពុជាដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ជាមួយជនបរទេសដែលកំពុងរស់នៅប្រទេសកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដោយត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ឯកសារថតចម្លងនៃលិខិតឆ្លងដែនរបស់សាមីជនបរទេស មានទិដ្ឋាការចូលប្រទេសកម្ពុជា ដែលមានសុពលភាព មានលិខិតបញ្ជាក់ភាពនៅលីវ ពោះម៉ាយ ឬមេម៉ាយ ដែលចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីជនបរទេស លិខិតបញ្ជាក់សុខភាព លិខិតថ្កោលទោស លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់ជនបរទេស ដែលអាចធានាដល់ជីវភាពរស់នៅ។

ប្រសិនបើមិនអនុវត្ត និងគោរពនូវគោលការណ៍នៃច្បាប់ខាងលើទេនោះ អាពាហ៍ពិពាហ៍ដែលមិនគោរពនោះនៅត្រូវចាត់ ទុកថាជាអាពាហ៍ពិពាហ៍ដែលផ្ទុយទៅនឹងច្បាប់កំណត់ដែលជាហេតុនាំឲ្យអាពាហ៍ពិពាហ៍លុបចោល។ អាចនិយាយម្យ៉ាងទៀតបានថាគ្មានការលុបចោលអាពាហ៍ពិពាហ៍ដោយគ្មានការស្នើសុំទៅតុលាការឡើយ បើនោះជាការអនុញ្ញាតឲ្យ រៀបអាពាហ៍ពិពាហ៍

[7] អនុក្រឹត្យស្តីពី អត្រានុកូលដ្ឋាន,លេខ១០៣ អនក្រ.បក,២៩ ធ្នូ ឆ្នាំ២០០០,មាត្រា៣០។

[8] អនុក្រឹត្យស្តីពីការកំណត់បែបបទនិងនីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស,លេខ១៨៣ អនក្រ.បក, ១២ ខែវិច្ឆិកា ឆ្នាំ២០០៨,មាត្រា១០។

ថាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន ដោយយោងតាមបញ្ញត្តិទូទៅ។ ជារួមមូលហេតុ នៃការលុប ចោលអាពាហ៍ពិពាហ៍ជាកម្មវត្ថុចម្បង នៃសារណាដែលក្នុងនោះនឹងត្រូវសិក្សាបង្ហាញទៅលើបញ្ហា មួយចំនួន

## ២៖ ចំណោទបញ្ហា

ជារួមមូលហេតុ នៃការលុប ចោលអាពាហ៍ពិពាហ៍ជាកម្មវត្ថុចម្បង នៃសារណារដែលក្នុង នោះនឹងត្រូវសិក្សាបង្ហាញទៅលើបញ្ហាមួយចំនួនជាអាទ៏៖

១.តើមានបុគ្គលណាខ្លះដែលមានសិទ្ធិស្នើសុំទាមទាឲ្យលុបចោលអាពាហ៍ពិពាហ៍?

២.តើការលុបចោលអាពាហ៍ពិពាហ៍ នឹងជួបផលវិបាកយ៉ាងដូចម្តេចខ្លះ?

## ៣៖ គោលបំណង

ការធ្វើការសិក្សាស្រាវជ្រាវសារណានេះ មានគោលបំណង សិក្សាស្វែងយល់ឲ្យច្បាស់អំពី ហេតុផលនានាក្នុងសង្គមកម្ពុជា ដែលនាំឲ្យកើតមានឡើងនូវ ការលុបចោលអាពហ៍ពិពាហ៍ ក្នុង គ្រួសារនីមួយៗនៅក្នុងប្រទេសកម្ពុជា និងរកឲ្យឃើញនូវមូលហេតុ វិជ្ជមាន អវិជ្ជមានដែលជា ឧបសគ្គក្នុងការ ប្តឹងតវ៉ាឲ្យលុបចោលនូវអាពាហ៍ពិពាហ៍ ដែលកើតឡើងហើយផ្ទុយពីបទបញ្ញតិ និងវិសាលភាពនៃច្បាប់កំណត់។ ការសិក្សាអំពី "**ការលុបចោលអាពាហ៍ពិពាហ៍**" នេះជាគោល បំណងដែលក្រុមយើងខ្ញុំ លើកយកមកសិក្សាដោយមូលហេតុចង់ពង្រឹងបន្ថែម លើសមត្ថភាពនៃចំ ណេះដឹងផ្ទាល់ខ្លួនរបស់ពួកយើងខ្ញុំ ឲ្យបានកាន់តែស៊ីជម្រៅនឹងជឿជាក់ថាអាចយកទៅប្រើប្រាស់ ក្នុងសង្គមជាពិសេសនៅក្នុងមូលដ្ឋានដែលយើងរស់នៅ នឹងផ្សព្វផ្សាយជាលក្ខណៈគ្រួសារ ឬចូល រួមការងារស្ម័គ្រចិត្ត ជាមួយយុទ្ធនាការផ្សព្វផ្សាយចំណេៈដឹងច្បាប់ក្នុងវិស័យអាពាហ៍ពិពាហ៍ឲ្យ ប្រជាពលរដ្ឋ ជាពិសេសបុគ្គលដែលមានវ័យអាចរៀបអាពាហ៍ពិពាហ៍បាន យល់ដឹងអំពីសិទ្ធិសេរី ភាពរបស់ខ្លួនក្នុងការរៀបចំគូជីវិតស្របតាមឆន្ទៈនិង បញ្ញត្តិច្បាប់ជាធរមាន មិនត្រឹមតែប៉ុណ្ណោះ សារណាមួយច្បាប់នេះ ក៏ចូលរួមចំណែកយ៉ាងសំខាន់សំរាប់ អ្នកសិក្សាស្រាវជ្រាវទាំងឡាយណា ដែល បានអាននូវខ្លឹមសារ ទាំងមូល សម្រាប់ជាទុនផ្នែក គំនិត បញ្ញានិងស្មារតីផងដែរ។

## ៤៖ ទំហំកំណត់ និងវិសាលភាព

ការស្រាវជ្រាវសារណា "**ការលុបចោលអាពាហ៍ពិពាហ៍**" គឺជាការសិក្សាស្រាវជ្រាវនិង ស្វែងរកពីមូលហេតុដែលនាំឲ្យមានការលុបចោលអាពាហ៍ពិពាហ៍ នៅកម្ពុជាសព្វថ្ងៃ។ ទំហំកំណត់

នៃការសិក្សាស្រាវជ្រាវសារណានេះគឺ អនុលោមទៅតាមច្បាប់កម្ពុជា ដែលបានចែងនៅក្នុង ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨២ ច្បាប់ស្តីពីឯកពន្ធភាព ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត និងបណ្តាប្រព័ន្ធផ្សព្វផ្សាយតាមអ៊ីនធើណែត(Internet) ជាច្រើន ផ្សេងទៀត។ វិសាលភាពនៃការស្រាវជ្រាវសារណាមួយច្បាប់នេះ គឺផ្តោតយ៉ាងខ្លាំងហើយសំខាន់ សំរាប់ការប្រើប្រាស់ប្រព័ន្ធយុត្តាធិការនៅក្នុងប្រទេសក៏ដូចជាក្រៅប្រទេសផងដែរ។

## ៥៖ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ ទៅលើសារណាថ្នាក់បរិញ្ញាបត្រនេះ ធ្វើឡើងស្របទៅតាមលក្ខណៈវិទ្យាសាស្ត្រ និងស្របទៅតាមនីតិវិធីគោលការណ៍នៃការសរសេរសារណា របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយមានការចុះកម្មសិក្សាស្រាវជ្រាវទៅដល់សាលាដំបូងខេត្តកណ្តាល ការស្វែងរកឯកសារផ្សេងតាមរយៈអ៊ីនធើណេត នៅក្នុងបណ្ណាល័យច្បាប់ បណ្ណាល័យជាតិ ជាពិសេសទទួលបានមតិណែនាំសំខាន់ៗពីសំណាក់ មិត្តភក្តិ សិស្សច្បង អ្នកគ្រូសាស្ត្រាចារ្យដឹកនាំសារណានេះ ក៏ដូចជាសាស្ត្រាចារ្យផ្សេងទៀតជាច្រើនផងដែរ។

## ៦៖ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះបានស្រាវជ្រាវឡើងនិងចងក្រងជាភាសាខ្មែរដែលក្នុងនោះចែកចេញជា ៣ជំពូក រួមមាន៖

ជំពូកទី១ និយាយអំពីមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ពលរដ្ឋខ្មែរនិងជនបរទេស អាជ្ញាយុកាលនៃការប្តឹងលុបចោល និងអ្នកដែលមានសិទ្ធប្តឹងឲ្យលុបចោល។

ជំពូកទី២ និយាយអំពីនីតិវិធីនៃការលុបចោលអាពាហ៍ពិពាហ៍ សមត្ថកិច្ចតុលាការ។

ជំពូកទី៣ គឺនិយាយអំពី អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍។

# ជំពូកទី១៖ ការលុបចោលអាពាហ៍ពិពាហ៍

## សញ្ញាណទូទៅនៃការលុបចោលអាពាហ៍ពិពាហ៍៖

ការរៀបអាពាហ៍ពិពាហ៍ គឺតែងតែមាននៅក្នុងជីវិតមនុស្សម្នាក់ ពីព្រោះថាអាពាហ៍ពិពាហ៍ជាចំណងសម្ព័ន្ធភាពរវាងបុរស ហើយនិងនារី ដូច្នេះបុរសនិងនារី ចាំបាច់ត្រូវតែពេញវ័យ ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ផ្លូវកាយ ផ្លូវចិត្ត ព្រមទាំងបញ្ញានិងស្មារតីផង។ ជាការកំណត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាយើង ដើម្បីរៀបអាពាហ៍ពិពាហ៍បានដោយត្រឹមត្រូវតាមច្បាប់ គឺត្រូវគោរពនូវលក្ខខណ្ឌមួយចំនួនដូចជា លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។ ពីព្រោះប្រសិនបើអាពាហ៍ពិពាហ៍មិនបានគោរពទៅតាមលក្ខណ្ឌនៃច្បាប់ទេ នោះអាចនាំឲ្យមានទណ្ឌកម្ម ដែលទណ្ឌកម្មទាំងនោះអាចកើតឡើង មុនពេលរៀបអាពាហ៍ពិពាហ៍ និងក្រោយពេលរៀបអាពាហ៍ពិពាហ៍។

ក្នុងករណីមុនពេលរៀបអាពាហ៍ពិពាហ៍ ឪពុកម្តាយ ឬបុគ្គលគ្រប់រូបដែលមានប្រយោជន៍ក្នុងនោះអាចធ្វើបណ្តឹងប្តឹងទាស់ទៅកាន់មន្ត្រីអាត្រានុកូលដ្ឋាន ដើម្បីឲ្យមន្ត្រីដែលមានសមត្ថកិច្ចបញ្ឈប់អាពាហ៍ពិពាហ៍នោះនិងរងចាំរហូតដល់បណ្តឹងទាស់នោះត្រូវបានដោះស្រាយចប់។ ប្រសិនបើតុលាការបដិសេធបណ្តឹងទាស់នោះចោល អនាគតប្តីប្រពន្ធអាចរៀបអាពាហ៍ពិពាហ៍បាន តែបើតុលាការចាត់ទុកបណ្តឹងនោះត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ឈប់អាពាហ៍ពិពាហ៍នោះ។

ទណ្ឌកម្មដែលកើតមានឡើងក្រោយការរៀបអាពាហ៍ពិពាហ៍គឺកើតឡើងដោយការមិនបានគោរពនិងបំពេញទៅតាមលក្ខខណ្ឌណាមួយដែលច្បាប់បានកំណត់នោះនាំឲ្យគេអាចធ្វើលុបចោលអាពាហ៍ពិពាហ៍នោះបាន។

ទាំងអស់ខាងលើនេះ ជាលក្ខខណ្ឌចាំបាច់ក្នុងការរៀបអាពាហ៍ពិពាហ៍ ដែលត្រឹមត្រូវតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យ៉ាងច្បាស់លាស់ក្នុងការអនុវត្ត។ ប្រសិនបើមិនអនុវត្តនិងគោរពនូវគោលការណ៍នៃច្បាប់ខាងលើទេនោះ អាពាហ៍ពិពាហ៍ដែលមិនគោរពនោះនៅត្រូវចាត់ទុកថាជាអាពាហ៍ពិពាហ៍ដែលផ្ទុយទៅនឹងច្បាប់កំណត់ ដែលជាហេតុនាំឲ្យ អាពាហ៍ពិពាហ៍នោះអាចលុបចោលបាន។ អាពាហ៍ពិពាហ៍ដែលអាចលុបចោលបានគឺជាការរំលាយអាពាហ៍ពិពាហ៍ដែលបានកើតមានឡើងហើយមានអានុភាពរួចហើយ មានន័យថា អាពាហ៍ពិពាហ៍នោះបានប្រព្រឹត្តឡើយដោយស្របតាមនីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍ គឺបានចុះបញ្ជីអាពាហ៍ពិពាហ៍ និងចុះកិច្ចសន្យាអាពាហ៍ពិពាហ៍រួចរាល់ស្របតាមច្បាប់កំណត់។

## ផ្នែកទី១. មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ

ការលុបចោលអាពាហ៍ពិពាហ៍ គឺជាការប្រកាសទោសទណ្ឌកម្មដែលលុបបំបាត់អានុភាពនៃអាពាហ៍ពិពាហ៍ ឆ្ពោះទៅពេលអនាគតទៅតាមផ្លូវតុលាការ ដោយសារតែច្បាប់បានហាមឃាត់អាពាហ៍ពិពាហ៍នោះ ទោះបីជាពួកគេមានឆន្ទៈរៀបអាពាហ៍ពិពាហ៍នោះក៏ដោយ។ អាពាហ៍ពិពាហ៍ដែលអាចលុបចោលបានមានន័យថា អាពាហ៍ពិពាហ៍ដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍រួចហើយក៏ប៉ុន្តែការចុះសំបុត្រអាពាហ៍ពិពាហ៍នោះមានលក្ខណៈមិនត្រឹមត្រូវតាមច្បាប់ ដែលជាហេតុនាំឲ្យភាគីនីមួយៗ អាចលុបចោលអាពាហ៍ពិពាហ៍នោះបាន។ អាពាហ៍ពិពាហ៍ដែលអាចលុបចោលបានគឺជាអាពាហ៍ពិពាហ៍មានលក្ខណៈ ផ្ទុយទៅនឹងបញ្ញត្តិច្បាប់ ដែលមានទាក់ទងនឹងផលប្រយោជន៍សាធារណៈ ពីមាត្រា៩៥៨ រហូតដល់មាត្រា៩៥២ និងផលប្រយោជន៍ឯកជន មាត្រា៩៦៣ នៃក្រមរដ្ឋប្បវេណី។ ការលុបចោលអាពាហ៍ពិពាហ៍គឺជាការរំលាយអាពាហ៍ពិពាហ៍ ដែលបានកើតមានឡើងហើយមាន អានុភាពរួចហើយ ពោលគឺអាពាហ៍ពិពាហ៍នោះបានប្រព្រឹត្ត ឡើងដោយស្របតាមនីតិវិធីក្នុងការ រៀបអាពាហ៍ពិពាហ៍ គឺបានចុះបញ្ជីអាពាហ៍ពិពាហ៍ និងចុះកិច្ចសន្យាអាពាហ៍ពិពាហ៍រួចរាល់នឹង ស្របទៅតាមច្បាប់កំណត់។

### ១.១. មិនគ្រប់អាយុរៀបអាពាហ៍ពិពាហ៍

កាលពីឆ្នាំ ១៩៨៩ ព្រះរាជាណាចក្រកម្ពុជាយើង បានបញ្ញត្តិថាបុរសអាយុចាប់ពី២០ឆ្នាំឡើងទៅ និងចំណែកឯនារី គឺអាយុចាប់ពី១៨ឆ្នាំឡើងទៅទើបមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ ជាមួយគ្នាបាន[9]។ ចំពោះច្បាប់កម្ពុជាបច្ចុប្បន្នបានកំណត់យក អាយុ១៨ឆ្នាំ ដែលជាអាយុដល់នីតិភាពមកជាអាយុអប្បបរមាដែលសមរម្យអាចរៀបអាពាហ៍ពិពាហ៍បាន។ ការកំណត់អំពីអាយុនៃបុគ្គលដែលរៀបអាពាហ៍ពិពាហ៍ គឺត្រូវបានកំណត់យ៉ាងច្បាស់ដោយមិនអនុញ្ញាតឲ្យបុគ្គលណាអាចបំពានអំពីលក្ខខណ្ឌមួយនេះបានឡើយ គឺលើកលែងតែករណីពិសេសមួយចំនួនតែប៉ុណ្ណោះ។ ការកំណត់អំពីអាយុនៃភាគីអាពាហ៍ពិពាហ៍ គឺដើម្បីតម្រូវឲ្យបុគ្គលដែលរៀបអាពាហ៍ពិពាហ៍មានគ្រប់លក្ខណៈសម្បត្តិគ្រប់គ្រាន់នូវ ភាពទទួលខុសត្រូវចំពោះគ្រួសារ មានកាយសម្បទាពេញលេញ មានបញ្ញាស្មារតីបរិបូរ មានមុខរបរចិញ្ចឹមជីវិតច្បាស់លាស់ មានទំនួលខុសត្រូវគ្រប់គ្រាន់ក្នុងការមើលថែរក្សាកូនជាដើម បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច។ យ៉ាងដូចនេះហើយ ទើបមានការហាមឃាត់ បុរស និងនារី ដែលមិនទាន់បានដល់នីតិភាព និងមិនទទួលបានអត្តាធីនភាពតាមច្បាប់ មិនអាចរៀបអាពាហ៍ពិពាហ៍បានទេ។

[9] ច្បាប់ស្តី ពីអាពាហ៍ពិពាហ៍ និងគ្រួសារ,លេខ៥៦ក្រ,២០ ខែកក្កដា ឆ្នាំ ១៩៨៩,មាត្រា៥។

## ១.២. អាពាហ៍ពិពាហ៍រវាងញាតិលោហិត

បុរស និងនារី ដែលជាភាគីនៃអាពាហ៍ពិពាហ៍ដែលបានដល់នីតិភាពហើយក្តី ក៏មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដែរ ប្រសិនបើភាគីទាំងសងខាងជាញាតិលោហិត ខ្សែផ្ទាល់ ឬសាខា ញាតិលោហិត ក្នុង៣ថ្នាក់រាប់ទាំងថ្នាក់ទី៣ផង[10]។ ការរៀបអាពាហ៍ពិពាហ៍ ជាមួយថ្នាក់ជិតគ្នាបែប នេះគឺត្រូវបានច្បាប់ហាមឃាត់ជាដាច់ខាត ចំពោះអាពាហ៍ពិពាហ៍រវាងគ្នានឹងគ្នា ដោយសារមូលហេតុនៃ សុជាតិវិទ្យា និងសីលធម៌សង្គម។ បើយោងទៅតាមមូលហេតុនៃសុជាតិវិទ្យា គឺការរៀបអាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិតគ្នា នឹងបណ្តាលអោយកូនដែលកើតមកមាន អាការៈខ្សោយ ប្រឈមមុខទៅនឹងជំងឺច្រើន ព្រមទាំងហានិភ័យនៃពិការភាព តាំងពីកំណើតខ្ពស់ជាងកុមារធម្មតា។ ដោយឡែកបញ្ហាសីលធម៌សង្គម ក៏ជាបញ្ហាដ៏ធំមួយផងដែរ ដោយវាផ្ទុយពីសីលធម៌សង្គម ហើយសង្គមក៏មិនទទួលស្គាល់អាពាហ៍ពិពាហ៍បែបនេះដូចគ្នា។ ជាការពិតណាស់ទោះបីជាមានការបញ្ចប់នូវញាតិភាព រវាងឪពុកម្តាយចិញ្ចឹម ចំពោះកូនស៊ុំពេញលេញឬកូនស៊ុំធម្មតា ហើយក្តីក៏ច្បាប់បានហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍នឹងគ្នាដែរ។ មួយវិញទៀតទោះបីមានការបញ្ចប់ទំនាក់ទំនងញាតិរវាង កូនស៊ុំនឹងឪពុកម្តាយបង្កើតបានកាត់ផ្តាច់ ដោយមូលហេតុនៃការបង្កើតកូនស៊ុំពេញលេញក៏ដោយក៏ទំនាក់ទំនងញាតិលោហិតតាមធម្មជាតិ មិនត្រូវបានកាត់ផ្តាច់ដែរ ដូចនេះហើយការហាមឃាត់រវាងអាពាហ៍ពិពាហ៍ថ្នាក់ជិតនៅតែត្រូវបានហាមឃាត់ដដែល ចំពោះចំណងញាតិលោហិតខ្សែផ្ទាល់។

## ១.៣. អាពាហ៍ពិពាហ៍រវាងញាតិពន្ធ

អាពាហ៍ពិពាហ៍មិនអាចធ្វើបានឡើយចំពោះញាតិពន្ធនៃខ្សែផ្ទាល់ និងរវាងសាខាញាតិពន្ធនៅក្នុង៣ថ្នាក់រាប់ទាំថ្នាក់ទី៣ផង។ ការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធខ្សែផ្ទាល់ និងរវាងជនដែលធ្លាប់ជាញាតិពន្ធខ្សែផ្ទាល់។ ដោយសារតែ ញាតិលោហិតនៃខ្សែផ្ទាល់របស់សហព័ទ្ធមានទំនាក់ទំនង ប្រហាក់ប្រហែលទៅនឹងញាតិលោហិតខ្សែផ្ទាល់របស់ខ្លួន ដែលស្រដៀងគ្នាទៅនឹងទំនាក់ទំនងឪពុកម្តាយ និងកូន ដូចនេះអាពាហ៍ពិពាហ៍បែបនេះក៏មិនមែនជាការគួរដែរ។ អាពាហ៍ពិពាហ៍ក៏មិនអាចធ្វើឡើងបានឡើយ រវាងញាតិពន្ធនៅក្នុង៣ថ្នាក់ ដោយរាប់ទាំងថ្នាក់ទី៣ផង ក៏ដោយក៏អាពាហ៍ពិពាហ៍នោះត្រូវបានហាមឃាត់ដែរ។ ពីព្រោះថានៅក្នុងសង្គមកម្ពុជា សាខាញាតិពន្ធទាំងនេះនិន្នាការបង្កើតទំនាក់ទំនងញាតិ ជារួម ដែលមានលក្ខណៈជិតស្និតស្រដៀងគ្នាទៅនឹងញាតិលោហិតខ្សែផ្ទាល់ និងសាខាញាតិលោហិតដែរ។ ក៏ប៉ុន្តែដោយសារទំនៀមទម្លាប់របស់

[10] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា៩៥១។

ប្រទេសកម្ពុជាយើង មានករណីអាពាហ៍ពិពាហ៍រវាងបងប្អូនថ្លៃ ដូចជាករណីដែលសហព័ទ្ធម្ខាងទទួលមរណភាពទៅ ហើយសហព័ទ្ធម្ខាងទៀតបានទៅរៀបអាពាហ៍ពិពាហ៍ជាមួយ បងឬប្អូនថ្លៃរបស់សហព័ទ្ធជាដើម។ ក្នុងគោលបំណងដើម្បីឲ្យជួយមើលថែរក្សា កូនរបស់បុគ្គលដែលទទួលមរណភាពនោះ។

## ១.៤. ទ្វេពន្ធភាព

បុរសដែលមានសហព័ន្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ[11] ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទទ្វេពន្ធភាព ប្រសិនបើបុរស ឬនារីណាដែលមានចំណងអាពាហ៍ពិពាហ៍មុនមិនទាន់បានរលាយនៅឡើយ ហើយទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត[12]។ ដោយសារការអនុម័តយករបបឯកពន្ធភាព បុរសត្រូវបានហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយនារីលើសពីមួយនាក់ ហើយចំណែកឯនារីក៏មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយបុរសលើសពីមួយនាក់បានដូចគ្នា។ អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្តប្ដីមួយ ប្រពន្ធមួយ[13] ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហេតុនេះក្រមរដ្ឋប្បវេណីបានហាមឃាត់ចំពោះ បុគ្គលដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយគឺ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានទេ។

## ១.៥. អាពាហ៍ពិពាហ៍អំឡុងពេលហាមឃាត់

ក្រោយពេលដែលអាពាហ៍ពិពាហ៍ចាស់ត្រូវបានរំលាយ នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន ប៉ុន្តែត្រូវស្ថិតនៅក្នុងភាពជាមេម៉ាយ រយៈពេល៣០០ថ្ងៃ គិតចាប់ពីពេលដែលអាពាហ៍ពិពាហ៍ចាស់ត្រូវបានរំលាយ ដោយមូលហេតុប្ដីស្លាប់ ឬពីថ្ងៃប្រកាសសាលក្រមដែលសម្រេចអំពី មោឃភាពនៃអាពាហ៍ពិពាហ៍ ឬពីថ្ងៃចេញសាលក្រមស្ថាពរនៃការលែងលះគ្នា ដោយយោងតាម មាត្រា៩ ច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ ឆ្នាំ១៩៨៩។ ក៏ប៉ុន្តែក្រមរដ្ឋប្បវេណីបច្ចុប្បន្ន បានកែប្រែអំពីអំឡុងពេលហាមឃាត់ គឺហាមឃាត់មិនឲ្យនារីរៀបអាពាហ៍ពិពាហ៍ថ្មីទៀតក្នុងអំឡុងពេល ១២០ថ្ងៃ ថ្ងៃបន្ទាប់ពីការរលាយ ឬការលុបចោលអាពាហ៍ពិពាហ៍មុន ហេតុនេះស្ត្រីដែលបានលែងលះជាមួយស្វាមីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានលុះត្រារយៈពេល១២០ថ្ងៃបានកន្លងផុត។អាពាហ៍ពិពាហ៍ទាំងឡាយណាដែលបានដាក់ ពាក្យសុំរៀបអាពាហ៍ពិពាហ៍ហើយបានរំលោភបំពាននូវចំណុចនេះគឺនឹងត្រូវ

---

[11] រដ្ឋធម្មនុញ្ញ,២៤ កញ្ញា ឆ្នាំ១៩៩៣,មាត្រា ៤៥។

[12] ច្បាប់ស្ដីពី ឯកពន្ធភាព,លេខ នស/រកម/១០០៦/០២៦,០១ កញ្ញា ២០០៦,មាត្រា៤។

[13] ច្បាប់ស្ដីពី ឯកពន្ធភាព,លេខ នស/រកម/១០០៦/០២៦,០១ កញ្ញា ២០០៦,មាត្រា២។

លុបចោល។ អំឡុងពេលហាមឃាត់ស្ត្រីមិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មី ជាអំឡុងពេលដែលច្បាប់កម្រិតសំរាប់ស្ត្រី ដើម្បីជៀស វាងពីបញ្ហាជាមួយគ្នាក្នុងការកំណត់អំពីបិតុភាព។

## ១.៦. អាពាហ៍ពិពាហ៍ដោយការឆបោក ឬគំរាម

បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍មានវិការៈក្នុងការបង្ហាញឆន្ទៈ ដោយការ ឆបោក ឬគំរាមកំហែងអាចទាមទារទៅ តុលាការឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន[14]។ ការឆបោក ឬការគំរាមគឺសំដៅលើការធ្វើឲ្យភាគីម្ខាងទៀត យល់ព្រមរៀបអាពាហ៍ពិពាហ៍ ដោយសារមធ្យោបាយដ៏ខ្លាំងក្លាមួយដែលខុសច្បាប់ ដោយការបោកប្រាស់ឲ្យជននោះធ្លាក់ទៅក្នុងការភាន់ច្រឡំ ឬធ្វើឲ្យជននោះធ្វើតាមដោយការជូនដំណឹងអំពីភាពអាក្រក់ទៅភាគីម្ខាងទៀត។ ការឆបោក ឬ ការគំរាមចាំបាច់ត្រូវតែមានភាពផ្ទុយច្បាប់ដែលមានកម្រិតខ្ពស់ វាកើតឡើងដោយមធ្យោបាយដែលបានប្រើប្រាស់មានលក្ខណៈឆបោក ពាក់ព័ន្ធទៅ នឹងអសមត្ថភាពផ្លូវភេទ ឬចំណុចសំខាន់ ផ្សេងទៀតជាសត្យានុម័ត ឬជាអត្តនោម័ត ឬដោយពាក្យសម្ដី ឬអំពើគំរាមកំហែងជាដើម។ បញ្ញត្តិនេះគឺជាការកំណត់អំពីមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ដែលមានលក្ខណៈជាផលប្រយោជន៍ឯកជនដើម្បីការពារអំពីផលប្រយោជន៍នៃភាគីអាពាហ៍ពិពាហ៍។

# ផ្នែកទី២. មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

ការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរ និងជនបរទេសត្រូវផ្អែកលើគោលណ៍ការស្ម័គ្រចិត្ត និងឆន្ទៈផ្ទាល់របស់សាមីខ្លួន និងត្រូវអនុវត្តទៅតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានាដែលមានចែងក្នុងព្រះរាជាណាចក្រកម្ពុជា។ ត្រូវបានហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ដែល បង្កើតឡើងតាមរយៈភ្នាក់ងាររើសគូស្រករ ឈ្មួញកណ្ដាល ឬក្រុមហ៊ុនធ្វើអាជីវកម្ម អាពាហ៍ពិពាហ៍បោកបញ្ឆោត ក្នុងគោលបំណងកេញប្រវ័ញ្ចពលកម្ម ជួញដូរមនុស្ស ឬធ្វើអាជីវកម្មផ្លូវភេទ។ ដូច្នេះប្រសិនបើភាគីដែលរៀបអាពាហ៍ពិពាហ៍ បានរំលោភបំពានទៅលើលក្ខខណ្ឌដែលមានចែងខាងលើនេះ អាពាហ៍ពិពាហ៍ដែលកើតឡើងហើយនោះនឹងត្រូវបានលុបចោល។

## ២.១. អាពាហ៍ពិពាហ៍ដោយគ្មានឆន្ទៈ ឬដោយបង្ខិតបង្ខំ

អាពាហ៍ពិពាហ៍ ត្រូវតែបង្កើតឡើងដោយភាគីនៃអាពាហ៍ពិពាហ៍មាន ឆន្ទៈពិតប្រាកដក្នុងការរៀបអាពាហ៍ពិពាហ៍។ ការបង្ហាញឆន្ទៈរបស់ឪពុកម្ដាយ មិនមែនជាលក្ខខណ្ឌគតិយុត្តក្នុងការ

[14] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា៩៦៣។

បង្កើតអាពាហ៍ពិពាហ៍នោះទេ។ អាពាហ៍ពិពាហ៍ដែលកើតឡើងដោយ ការបង្ហាញឆន្ទៈរបស់ឪពុកម្តាយគឺជាអាពាហ៍ពិពាហ៍ ដែលមិនបានកើតឡើងក្នុងឆន្ទៈដ៏ពិតរបស់គូភាគីទេ។ អាពាហ៍ពិពាហ៍ដែលស្របច្បាប់ដាច់ខាតគឺត្រូវតែធ្វើឡើងដោយគ្មានការបង្ខិតបង្ខំ គំរាមកំហែង និងការបន្លំបោកប្រាស់ពីសំណាក់ភាគីម្ខាងទៀតនៃអាពាហ៍ពិពាហ៍ ឬតតិយជននោះទេ។ ដើម្បីជាការបញ្ជាក់អំពីការព្រមព្រៀងនៃភាគីដែលរៀបអាពាហ៍ពិពាហ៍ ថាអាពាហ៍ពិពាហ៍នោះកើតឡើងដោយឆន្ទៈឯកភាពគ្នារវាងភាគីខ្មែរ និងជនបរទេស គឺភាគីទាំងសងខាងត្រូវទៅបង្ហាញឆន្ទៈរបស់ខ្លួននៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ខាងលំនៅដ្ឋានរបស់ភាគីដែលជាពលរដ្ឋខ្មែរ ដោយការបង្ហាញឆន្ទៈនោះភាគីទាំងសងខាង ត្រូវស្ថិតនៅក្នុងសភាពដឹងខុស ដឹងត្រូវ មិនស្ថិតក្នុងស្ថានភាពស្រវឹង ឬភាពវង្វេងវង្វាន់ស្មារតី ឬស្ថិតនៅក្នុងអំណាចនៃថ្នាំសណ្តំ។ល។ ក្នុងន័យជាមួយគ្នានេះដែរនៅក្នុងអនុក្រឹត្យលេខ១៨៣ អនក្រ.បកចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ក៏បានបញ្ញត្តិយ៉ាង តឹងតែងដោយពិសេសចំពោះការរៀបអាពាហ៍ពិពាហ៍ រវាងជនជាតិខ្មែរនិង ជនបរទេស ដោយត្រូវឈរលើគោលការណ៍ស្ម័គ្រចិត្ត និងឆន្ទៈផ្ទាល់របស់សាមីជន និងត្រូវអនុវត្តទៅតាមល័ក្ខខ័ណ្ឌ ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។[15]

## ២.២. អាពាហ៍ពិពាហ៍ដោយភ្នាក់ងាររើសគូស្រករ

ដោយមូលហេតុថាមានករណី មួយចំនួនធំដែលកើតមានឡើងនៅក្នុងប្រទេស សព្វថ្ងៃគឺមានការលួចឃុបឃិតគ្នា រវាងជនជាតិខ្មែរនិងជនបរទេស បង្កើតជាបណ្តាញទំនាក់ទំនង លួចរៀបអាពាហ៍ពិពាហ៍នៅកម្ពុជា ហើយពេលដែលបានទៅដល់ប្រទេសគោលដៅទើបលែងលះគ្នាគេធ្វើទង្វើបែបនេះដើម្បីឲ្យខ្លួនបាន ទៅរស់នៅបរទេសដើម្បីធ្វើការរកលុយ ឬដើម្បី ទៅរស់នៅទីនោះដោយស្របច្បាប់ ក្នុងគោលបំណងទទួលបាន សញ្ជាតិពីបណ្តាប្រទេសផ្សេងៗ ដែលជាក់ស្តែងមានដូចជា ប្រទេសអាមេរិក អូស្ត្រាលី បារាំង កាណាដា ជាដើម។ នៅពេលដែល បានទទួលសញ្ជាតិរួចហើយគឺគេមកធានាសាច់ញាតិដូចជា ឪពុកម្តាយ បងប្អូនឲ្យទៅរស់នៅជា មួយគ្នា។ យ៉ាងដូច្នេះហើយទើប ច្បាប់នៃព្រះរាជាណាចក្របានបញ្ញតិ ហាមឃាត់ដាច់ខាតចំពោះ អាពាហ៍ពិពាហ៍ ដែលធ្វើឡើងតាមរយៈភ្នាក់ងាររើសគូស្រករ ឈ្មួយកណ្តាល ឬក្រុមហ៊ុន អាជីវកម្ម។ [16]

---

[15] អនុក្រឹត្យស្តីពីការកំណត់បែបបទនិងនីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស,លេខ១៨៣ អនក្រ.បក, ១២ ខែវិច្ឆិការ ឆ្នាំ២០០៨,មាត្រា២។

[16] អនុក្រឹត្យស្តីពី ការកំណត់បែបបទ និងនីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ,លេខ១៨៣ អនក្រ.បក, ១២ ខែវិច្ឆិការ ឆ្នាំ២០០៨,មាត្រា៣។

### ២.៣. អាពាហ៍ពិពាហ៍ដោយការឆបោក

ស្ត្រីកម្ពុជាមួយចំនួនបានលង់ចាញ់បោក ល្បិចកលរបស់ជនបរទេស មួយចំនួនថាគេពិតជាមានចិត្តស្រលាញ់ដោយស្ម័គ្រស្មោះ អស់ពីដួងចិត្ត និងមានបំណងរៀបអាពាហ៍ពិពាហ៍ ដើម្បីយកទៅនៅប្រទេសរបស់ជននោះដោយត្រឹមត្រូវតាមច្បាប់។ ភាពក្រីក្រតួនាទី និងភារកិច្ច ត្រូវចិញ្ចឹមបីបាច់ថែរក្សាគ្រួសារផង ទើបធ្វើឲ្យពួកគេសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ ជាមួយជនបរទេស ដើម្បីទៅរស់នៅនិងធ្វើការនៅទៅនោះ ក្នុងបំណងយកថវិការដែលរកបាននោះ ផ្ញើរមកស្រុកសម្រាប់ទ្រទ្រង់ ជីវភាពរស់នៅ ទើបធ្វើឲ្យស្ត្រីទាំងនោះ សម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសដោយ មិនបានដឹងនិងមិនគិតអំពី សាវតារបស់ជនបរទេសនោះឡើយ ទើបធ្វើឲ្យស្ត្រីនោះចាញ់ល្បិច បោក បញ្ឆោតយក ពួកគេទៅជួញដូរ ធ្វើជាទាសករ ធ្វើជាអ្នកបម្រើផ្ទះគេ ឬ ធ្វើអាជីវកម្មផ្លូវភេទជាដើម ដែលទង្វើទាំងនោះ សុទ្ធសឹងតែជាទង្វើខុសច្បាប់។ ដោយសារភាពមិនប្រក្រតីទាំងនេះទើបធ្វើឲ្យរាជរដ្ឋាភិបាល សម្រេចបង្កើតនូវច្បាប់អំពីការ ហាមឃាត់ជាដាច់ខាត ដោយចំពោះអាពាហ៍ពិពាហ៍ដែល ក្លែងក្លាយ បោកបញ្ឆោតក្នុងគោលបំណងកេងប្រវ័ញ្ចពលកម្ម ជួញដូរមនុស្ស ឬធ្វើអាជីវកម្មផ្លូវភេទ។[17]

## ផ្នែកទី៣. អាជ្ញាយុកាលនៃការប្តឹងលុបចោលអាពាហ៍ពិពាហ៍

នៅក្នុងទំនាក់ទំនងគតិយុត្តទូទៅ ករណីមាននូវមូលហេតុនៃការលុបចោលនោះអ្នកដែលមានសិទ្ធិត្រូវអនុវត្តសិទ្ធិក្នុងអំឡុងពេលនៃអាជ្ញាយុកាលកំណត់។ ប៉ុន្តែប្រសិនក្នុងករណីនៃការប្តឹងលុបចោលអាពាហ៍ពិពាហ៍ជាគោលការណ៍មិនមានរយៈពេលកំណត់ទេ គឺអ្នកដែលមានសិទ្ធក្នុងការប្តឹងអាចដាក់ពាក្យបណ្តឹងបាន នៅពេលដែលខ្លួនបានដឹង អំពីការមិនស្របតាមច្បាប់នៃអាពាហ៍ពិពាហ៍របស់ខ្លួន ហើយភាគីមានបំណងចង់លុបចោលនូវ អាពាហ៍ពិពាហ៍ដែលខុសច្បាប់នោះ។ ក៏ប៉ុន្តែលើកលែងតែការប្តឹងលុបចោល អាពាហ៍ពិពាហ៍ដោយមូលហេតុអាយុ អំឡុងពេលហាមឃាត់ស្ត្រី និងការឆបោក ឬគំរាមប៉ុណ្ណោះ ទើបមានការកំណត់អំពី អំឡុងពេលច្បាស់លាស់ក្នុងការប្តឹងទាមទារឲ្យលុបចោល។

### ៣.១. អាជ្ញាយុកាលដែលកំណត់ដោយច្បាប់

នៅពេលដែលជនមិនគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានដល់អាយុរៀបអាពាហ៍ពិពាហ៍សិទ្ធិដែលអាចទាមទារឲ្យលុបចោលក៏ត្រូវបានរលត់ដោយមូលហេតុថា ការបំពានលើលក្ខខណ្ឌក្នុង

[17] អនុក្រឹត្យស្តីពី ការកំណត់បែបបទ និងនីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ,លេខ១៨៣ អនក្រ.បក, ១២ ខែវិច្ឆិការ ឆ្នាំ២០០៨,មាត្រា៩។

ការរៀបអាពាហ៍ពិពាហ៍ត្រូវបានជួសជុលរួចហើយ ដូច្នេះវាលែងប្រឆាំងទៅនឹងសង្គមទៀតហើយ ទោះបីជាជនក្រៅពីភាគីអនុវត្តសិទ្ធិលុបចោលក៏ដោយ ក៏ភាគីនៃអាពាហ៍ពិពាហ៍នោះ នៅតែអាចរៀបអាពាហ៍ពិពាហ៍ម្តងទៀតបានដដែល។ ជនដែលបានរៀបអាពាហ៍ពិពាហ៍ មិនអាចយកមូលហេតុអាយុដើម្បីប្តឹងលុបចោលអាពាហ៍ពិពាហ៍ទេ បើកាលណាអនីតិជននោះបានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ។ ទោះជាយ៉ាងនេះក្តីជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ មានសិទ្ធិលុបចោលអាពាហ៍ពិពាហ៍ និងធ្វើសច្ចានុមតិ[18]ក្នុងអំឡុងពេលបីខែ បន្ទាប់ពីជននោះបានដល់អាយុរៀបអាពាហ៍ពិពាហ៍។ ការលុបចោលអាពាហ៍ពិពាហ៍ ដោយមូលហេតុអាយុនេះវាមានជាផលប្រយោជន៍សម្រាប់ឯកជន ដូចនេះហើយ សិទ្ធិលុបចោលនឹងត្រូវរលត់បន្ទាប់ពី សាមីជនបានផ្តល់សច្ចានុមតិក្នុងអំឡុពេល បីខែនោះ។

## ៣.២. អាជ្ញាយុកាលដែលកើតឡើងដោយការបន្ទាញឆន្ទៈ

### ៣.២.១. មូលហេតុស្ថិតក្នុងអំឡុងពេលហាមឃាត់

អាពាហ៍ពិពាហ៍ដែលបានធ្វើឡើងដោយផ្ទុយទៅនឹងបញ្ញត្តិនៃមាត្រា ៩៥០ ដែលមានបញ្ញត្តិស្តីពីអំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត គឺពុំអាចទាមទារឲ្យលុបចោលនូវអាពាហ៍ពិពាហ៍នោះបានឡើយ ប្រសិនរយៈពេល១២០ថ្ងៃ បានកន្លងផុត។ ថ្វីត្បិតតែច្បាប់បានទុករយៈពេលសម្រាប់ការលុបចោលក៏ពិតមែន ប៉ុន្តែសិទ្ធិលុបចោលនោះនឹងត្រូវរលត់នៅរយៈពេល ១២០ថ្ងៃ នៅពេលដែលរកឃើញថានារីនោះគ្មានផ្ទៃពោះ ។ សិទ្ធិលុបចោលនោះក៏ត្រូវបានរលត់ផងដែរ ក្នុងករណីនៅពេលដែលនារីនោះមានផ្ទៃពោះក្រោយការរៀបអាពាហ៍ពិពាហ៍ថ្មី។

### ៣.២.២. មូលហេតុឆបោក ឬគំរាម

ការឆបោកឬការគំរាម ជាមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ ដែលមានលក្ខណៈជាផលប្រយោជន៍ឯកជន ដូចច្នេះសិទ្ធិលុបចោលនឹងត្រូវរលត់ នៅពេលដែលភាគីបានធ្វើសច្ចានុមតិ ឬបើអំឡុងពេល បីខែ គិតចាប់ពីពេលដែលភាគីបានរកឃើញ អំពីការឆបោក ឬ រួចផុតខ្លួនអំពីការគំរាមបានកន្លងផុតទៅ។

# ផ្នែកទី៤. អ្នកមានសិទ្ធិទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍

ដោយសារតែករណីលុបចោលអាពាហ៍ពិពាហ៍មានលក្ខណៈខុសគ្នាពីមោឃភាពដែលមិនបាត់បង់អានុភាពដោយស្វ័យប្រវត្តនោះទេ គឺត្រូវឲ្យមានអ្នកប្តឹងទាមទារទៅតាមផ្លូវតុលាការហេតុ

[18] ការយល់ព្រមទទួលស្គាល់ដោយគ្នាអនុភាពប្រតិសកម្ម។

នេះហើយទើបច្បាប់កំណត់ឲ្យបុគ្គលមួយចំនួនដែល ជាអ្នកមានសិទ្ធិប្តឹងទាមទារឲ្យលុបចោលនូវអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវទាំងនោះ។ អ្នកមានសិទ្ធិទាមទារឲ្យលុបចោលត្រូវបានប្រែប្រួលទៅតាមមូលហេតុនៃការលុបចោល ដូចនេះអ្នកដែលមានសិទ្ធិត្រូវធ្វើ ការលុបចោលតាមរយៈបណ្តឹងទាមទារឲ្យលុបចោល។

## ៤.១. ភាគីដែលរៀបអាពាហ៍ពិពាហ៍

ភាគីដែលបានរៀបអាពាហ៍ពិពាហ៍ មានសិទ្ធិទាមទារឲ្យលុបចោលនូវអាពាហ៍ពិពាហ៍នៅពេល ដែលបានដឹងអំពីភាពមិនប្រក្រតីចំពោះអាពាហ៍ពិពាហ៍របស់ខ្លួនដែលមានលក្ខខណ្ឌចាំបាច់ក្នុងការ ហាមឃាត់ដូចជា មិនបានគ្រប់អាយុក្នុងការ រៀបអាពាហ៍ពិពាហ៍ អាពាហ៍ពិពាហ៍ជាមួយនឹងញាតិលោហិត ឬញាតិពន្ធ មិនឲ្យមានទ្វេពន្ធភាព អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មី ។

មានតែភាគីដែលរៀបអាពាហ៍ពិពាហ៍ដោយផ្ទាល់ទេ ទើបមានសិទ្ធិដាក់ពាក្យបណ្តឹងទាមទារឲ្យលុបចោលនោះបាន។ បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ដោយការឆបោក ឬការគំរាមអាចធ្វើការទាមទារទៅ តុលាការឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន។[19] ដើម្បីការពារជនដែលបានរៀបអាពាហ៍ពិពាហ៍ ដោយការឆបោក ឬគំរាម សិទ្ធិលុបចោលអាពាហ៍ពិពាហ៍ត្រូវបានផ្តល់ឲ្យតែចំពោះភាគីនៃអាពាហ៍ពិពាហ៍ តែប៉ុណ្ណោះដែលត្រូវបានប្រគល់ឲ្យ។ ភាគីម្ខាងនៃការលុបចោលគឺជាភាគីម្ខាងទៀតនៃអាពាហ៍ពិពាហ៍ ដោយរាប់បញ្ចូលទាំងករណីឆបោក ឬការគំរាមដែលត្រូវបានធ្វើឡើងដោយតតិយជនផងដែរ។

## ៤.២. ញាតិសណ្តានរបស់ភាគី

សាច់ញាតិរបស់ភាគីនីមួយៗ ក៏អាចដាក់ពាក្យបណ្តឹងឲ្យលុបចោលអាពាហ៍ពិពាហ៍បានដូចគ្នាប្រសិនបើដឹងថា អាពាហ៍ពិពាហ៍នោះបានផ្ទុយពីបញ្ញតិនៃ មាត្រា៩៦០ នៃក្រមរដ្ឋប្បវេណីដែលមានចែងអំពីការលុបចោលអាពាហ៍ពិពាហ៍ដែល មិនត្រឹមត្រូវតាមច្បាប់កំណត់។ ដោយគ្រាន់តែដាក់ពាក្យបណ្តឹងទាមទាឲ្យលុបចោលអាពាហ៍ពិពាហ៍ ទៅកាន់សាលាដំបូង រាជធានី ខេត្តរបស់ភាគីរស់នៅ។

[19] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា៩៦៣។

## ៤.៣. តំណាងអយ្យការ

មានតែនៅក្នុងបណ្តឹងដែលទាក់ទងទៅនឹងឋានៈបុគ្គលទេ ដែលព្រះរាជអាជ្ញាអាចចូលរួមក្នុងនីតិវិធីនៃបណ្តឹងបាន។ ជាធម្មតាក្នុងនីតិវិធីនៃបណ្តឹង ព្រះរាជអាជ្ញាគ្មានសិទ្ធិចូលរួមនោះទេ។ តំណាង អយ្យការអាចដាក់ពាក្យបណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍បាន [20] ប្រសិនបើយល់ឃើញ ថាចាំបាច់តែត្រូវការពារដល់ផលប្រយោជន៍សាធារណៈ [21] និងអំពីបុគ្គលដែលមានសិទ្ធិទាមទារឲ្យលុបចោល។ ម៉្យាងទៀតត្រូវកំណត់ផងដែរ អំពីការទាមទារត្រូវធ្វើឡើងដោយការដាក់ពាក្យបណ្តឹងទៅតុលាការ ដោយសារតែអនុភាពនៃការលុបចោលអាពាហ៍ពិពាហ៍ ចាំបាច់ត្រូវធ្វើការកំណត់ជាស្ថាពរឲ្យមាន លក្ខណៈជាឯកសណ្ឋាន។ ក្នុងករណីដែលភាគីគឺជាអនីតិជនជាដើម អ្នកដែលមាន តួនាទីត្រូវការពារភាគីនោះ មិនមែនជាព្រះរាជអាជ្ញាទេតែគឺជាអ្នកតំណាងដែលច្បាប់បានកំណត់ មានដូចជា អ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលជាដើម។ តំណាងអយ្យាការដែលជាអ្នកតំណាង ឲ្យផលប្រយោជន៍សាធារណៈ សិទ្ធិទាមទារឲ្យលុបចោលរបស់ តំណាងអយ្យការនោះ នឹងត្រូវរលត់ប្រសិនបើសហព័ទ្ធម្ខាងទទួលមរណៈភាព។

## ៤.៤. ទ្វេពន្ធភាព

ចំពោះករណីទ្វេពន្ធភាព ឬការបំពានអំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីវិញ សហព័ទ្ធរបស់ភាគី ឬសហព័ទ្ធនៃអាពាហ៍ពិពាហ៍មុន ក៏អាចទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍បានដែរ។[22] នៅពេលដែលអាពាហ៍ពិពាហ៍ចាស់មិនទាន់បានរលត់ ជាស្ថាពរនៅឡើយ ហើយភាគីម្ខាងបានលួចលាក់ទៅរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀត សហព័ទ្ធម្ខាងដែលជាភាគីនៃអាពាហ៍ពិពាហ៍ចាស់ ក៏មានសិទ្ធិទាមទាឲ្យលុបចោលអាពាហ៍ថ្មីនោះបាន ដោយមូលហេតុអាពាហ៍ពិពាហ៍ចាស់មិនទាន់បានរលត់ជាស្ថាពរ តាមរយៈសាលក្រមរបស់តុលាការ។

[20] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា៩៦០។

[21] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦,មាត្រា៦។

[22] ដូច២០។

## ជំពូកទី២៖ នីតិវិធីនៃការលុបចោលអាពាហ៍ពិពាហ៍

ភាគីដែលមានបំណងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។[23] បណ្តឹងទាក់ទងនឹងឋានៈបុគ្គល មានគោលបំណងបង្កើត ឬ បញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងឋានៈបុគ្គល ពោលគឺសំដៅទៅលើបណ្តឹងដែលបង្កើត អានុភាពនូវការបង្កើត អានុភាពកំណត់ជាស្ថាពរនូវអត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងឋានៈបុគ្គលបច្ចុប្បន្នកាល ឬ អតីតកាល តាមរយៈសាលក្រម ឬ សាលដីកាស្ថាពរដែលទទួលស្គាល់នូវការ ទាមទារក្នុងបណ្តឹងនោះដូចជា បណ្តឹងបញ្ជាក់អំពី អត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ ឬ នត្ថិភាពនៃទំនាក់ទំនងបិតុភាព(មាតុភាព) ជាដើម។

### ផ្នែកទី១៖ សមត្ថកិច្ចតុលាការ

ការកំណត់ជាស្ថាពរនូវទំនាក់ទំនងប្តីប្រពន្ធ តាមបណ្តឹងទាមទារឲ្យលុបចោអាពាហ៍ពិពាហ៍ មានលក្ខណៈជាផលប្រយោជន៍សាធារណៈ ហេតុនេះ ចាំបាច់ត្រូវសម្របទៅនឹងតម្រូវការ ក្នុងការស្វែងរកការពិតជាក់ស្តែង ព្រមទាំងតម្រូវការក្នុងការរកដំណោះស្រាយវិវាទទាំងស្រុង តាមរយៈការវិនិច្ឆ័យតែមួយលើក។ ដូច្នេះហើយ ចាំបាច់ត្រូវកំណត់ឲ្យបានច្បាស់លាស់នូវតុលាការដែលចាត់ការបណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍នេះ ហើយធ្វើការកំណត់នូវ ដែនសមត្ថកិច្ចរបស់តុលាការឲ្យបានច្បាស់លាស់ ដោយកំណត់យកទីកន្លែងដែលអាចមានសាមីភាគី ញាតិ ឬ មិត្តភក្តិ ជាអាទិ៍ ដែលជាភស្តុតាងល្អៗ ដើម្បីសម្រួលនូវការធ្វើការអះអាង និង បញ្ជាក់របស់ភាគី និង សម្រួលនូវការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់តុលាការ គឺជាការសមរម្យ។ ជាលទ្ធផលច្បាប់បានកំណត់យក សមត្ថកិច្ចតុលាការផ្តាច់មុខរបស់សាលាដំបូង ដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីដែលពាក់ព័ន្ធនឹងបណ្តឹងនេះ [24] ក្នុងការដោះស្រាយវិវាទ។ ប៉ុន្តែបើលំនៅឋានរបស់ភាគីពុំស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ លំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនពិតប្រាកដទេសមត្ថកិច្ចសាលាជម្រះក្តីត្រូវកំណត់តាមទីសំណាក់។ បើពុំមានទីសំណាក់ ឬ ទីសំណាក់មិនពិតប្រាកដទេ សមត្ថកិច្ចនោះត្រូវកំណត់តាមលំនៅឋានចុងក្រោយ ។[25] ក្នុងករណីមិនអាចកំណត់តុលាការមានសមត្ថកិច្ចបាន បណ្តឹងទាក់ទងនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងរាជធានីភ្នំពេញ។[26] ប្រសិនបើតុលាការយល់ឃើញថាចាំបាច់ ដើម្បីចៀសវាងពី

[23] ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល,លេខ នស/រកម/០៦១០/០០៨,៨ មិថុនា ២០១០,មាត្រា៣។

[24] ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល,លេខ នស/រកម/០៦១០/០០៨,៨ មិថុនា ២០១០,មាត្រា៥។

[25] ដូច ២៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

[26] ដូច២៤ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

ការយឺតយ៉ាវនៃនីតិវិធី ឬដើម្បីឲ្យមានសមធម៌រវាងគូភាគីតុលាការអាចផ្ទេរបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទាំងមូល ឬផ្នែកណាមួយ ទៅតុលាការផ្សេងទៀតដែលមានសមត្ថកិច្ចតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិបានដោយពិចារណាអំពីលំនៅឋានរបស់ភាគី និងសាក្សីដែលត្រូវសាកសួរ និងកាលៈទេសៈផ្សេងៗ ទោះបីបណ្តឹងនោះស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ។[27]

## ផ្នែកទី២៖ បណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍

បណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ គឺជាបណ្តឹងទាមទារឲ្យតុលាការចេញសាលក្រមប្រកាសរំលត់នូវចំណងអាពាហ៍ពិពាហ៍ ដោយផ្អែកលើមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តនោះ។ ជាគោលការណ៍សកម្មភាពនៃបណ្តឹងនេះ ត្រូវធ្វើឡើងតាមវិធីដាក់ពាក្យ បណ្តឹង ។

### ២.១. ការដាក់ពាក្យបណ្តឹង

#### ២.១.១. របៀបដាក់ពាក្យបណ្តឹង

ពេលដែលភាគី ឬ តតិយជនបានដឹងថាអាពាហ៍ពិពាហ៍បានកើតឡើងដោយ បំពានល័ក្ខខ័ណ្ឌណាមួយ បុគ្គលនោះអាចដាក់ពាក្យបណ្តឹងទៅតុលាការបាន ពោលគឺនីតិវិធីបណ្តឹងត្រូវចាប់ផ្តើមពីពេលដែលមានការដាក់ពាក្យបណ្តឹងកើតឡើង។ ការដាក់បណ្តឹងត្រូវធ្វើឡើងដោយពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅតុលាការ។[28] មានន័យថាការប្តឹង គឺជាសកម្មភាពមួយដែលទាមទារឲ្យមានការបំពេញនូវលក្ខខណ្ឌជាក់លាក់មួយជាកំណត់ នោះគឺការប្រគល់នូវពាក្យបណ្តឹង ដើម្បីបង្ហាប់ឲ្យបានច្បាស់លាស់នូវអង្គហេតុនៃការធ្វើបណ្តឹងតាមនីតិវិធី។

#### ២.១.២. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង

- **ចំណុចដែលចាំបាច់ត្រូវសរសេរបញ្ជាក់**

ចំណុចដែលចាំបាច់ត្រូវសរសេរបញ្ជាក់នៃពាក្យបណ្តឹងជា ចំណុចដែលត្រូវសរសេរដើម្បីឲ្យពាក្យបណ្តឹងមានសុពលភាព។ពេលខ្វះចំណុចនេះពាក្យបណ្តឹងនឹងគ្មានសុពលភាពនោះ តុលាការត្រូវបង្គាប់ឲ្យកែតម្រូវនូវកង្វះខាតនេះប្រសិនបើមិនបានធ្វើការកែតម្រូវទេតុលាការ ត្រូវលើកបណ្តឹងនោះចោល។[29]

ចំណុចដែលត្រូវសរសេរក្រៅពីនេះរួមមាន៖

[27] ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល,លេខ នស/រកម/០៦១០/០០៨,៨ មិថុនា ២០១០,មាត្រា៦។

[28] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៧៥ កថាខណ្ឌទី១។

[29] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៧៨។

- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ព្រមទាំង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ
- អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ។[30]

- **ចំណុចដែលត្រូវសរសេរក្រៅពីនេះ**

ចំណុចដែលត្រូវសរសេរក្រៅពីចំណុចចាំបាច់ដែលត្រូវសរសេរបញ្ជាក់ជាចំណុចដែលត្រូវសរសេរដោយស្ម័គ្រចិត្ត។ វាមិនមែនជាចំណុចសុពលភាពនៃបណ្តឹងទេ ប៉ុន្តែដើមចោទគប្បីសរសេរចំណុចនេះដើម្បីជាមូលដ្ឋាននៃការឆ្លើយតបរបស់ចុងចម្លើយ និងជៀសវាងការយឺតយ៉ាវ។

ចំណុចត្រូវសរសេររួមមាន៖

- អង្គហេតុដែលជាមូលហេតុនៃការទាមទាររបស់ដើមចោទ (អង្គហេតុចម្បង)[31]
- អង្គហេតុសំខាន់ៗដែលពាក់ព័ន្ធនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ
- ភស្តុតាង មធ្យោបាយតទល់ ឬការពារខ្លួន
- កាលបរិច្ឆេទ ហត្ថលេខា

គួរបញ្ជាក់ផងដែរថា ពាក្យបណ្តឹងមិនអាចលើកចោលដោយហេតុខ្វះនូវចំណុចទាំងនេះទេ។

## ផ្នែកទី៣៖ ការបង់ពន្ធប្រាក់ប្រដាប់ក្តី

ប្រាក់ប្រដាប់ក្តី គឺជាប្រាក់ពន្ធ ឬសោហ៊ុយដែលភាគីត្រូវបង់សម្រាប់ចាត់ការរឿងក្តីរបស់ខ្លួនទៅតុលាការតាមបញ្ញត្តិច្បាប់។ ប្រាក់ប្រដាប់ក្តីត្រូវគណនា ដោយផ្អែកលើមូលដ្ឋាននៃផលប្រយោជន៍ដែលបានទាមទារក្នុងបណ្តឹងនោះ។ ការទាមទារច្រើនចំណុចក្នុងបណ្តឹងតែមួយ តម្លៃសរុបនៃការទាមទារទាំងនោះ ត្រូវបានចាត់ទុកជាតម្លៃកម្មវត្ថុនៃបណ្តឹង។[32] ក្នុងករណីដែលមានការពិបាកក្នុងការគណនាតម្លៃដែលបានកំណត់ខាងលើ តុលាការត្រូវកំណត់តម្លៃនោះ ដោយឆន្ទានុសិទ្ធិសមហេតុផល។ បើតម្លៃនោះមិនអាចគណនាបានទេ នោះត្រូវចាត់ទុកថា មានចំនួន ៥.៥០០.០០០ (ប្រាំលានប្រាំសែន) រៀល។[33]

### ៣.១. ប្រភេទប្រាក់ប្រដាប់ក្តី

[30] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៧៥ កថាខណ្ឌទី២។
[31] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៧៥ កថាខណ្ឌទី៣។
[32] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦០ កថាខណ្ឌទី១។
[33] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦០ កថាខណ្ឌទី៣។

**ពន្ធដាក់ពាក្យសុំ៖** គឺជាប្រាក់ពន្ធដែលភាគីត្រូវបង់ក្នុងការដាក់ពាក្យបណ្តឹង ឬពាក្យសុំ សម្រាប់ចាត់ ការរឿងក្តីរបស់ខ្លួនទៅតុលាការតាមបញ្ញត្តិច្បាប់រួមមាន ពន្ធដាក់ពាក្យបណ្តឹង និងពន្ធដាក់ពាក្យសុំ។ ចំនួនទឹកប្រាក់ដែលត្រូវបង់ពន្ធ ត្រូវគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្តឹង។[34] ការបង់ពន្ធត្រូវធ្វើ ដោយដោយការបង់ជាប្រាក់នៅកន្លែងទទួលពាក្យនៃតុលាការ។ ពាក្យសុំដែល មិនបានបង់ពន្ធនៅពេលដាក់ទេ ត្រូវចាត់ទុកជាពាក្យសុំមិនស្របច្បាប់។[35]

**ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ៖** គឺជាប្រាក់ប្រដាប់ក្តីតុលាការដែលភាគី ឬបុគ្គលដែល ទាក់ទង នឹងរឿងក្តីត្រូវបង់ជាមុនសម្រាប់ការចំណាយរបស់តុលាការដែល ធ្វើសកម្មភាពតាម នីតិវិធីនៅក្នុង បណ្តឹងរដ្ឋប្បវេណី។ សកម្មភាពតាមនីតិវិធី នៅក្នុងបណ្តឹងរដ្ឋប្បវេណីមានដូចជា៖ ការពិនិត្យ ភស្តុតាង ការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងៗតាមនីតិវិធីក្នុងបណ្តឹងរដ្ឋប្បវេណី សោហ៊ុយ សម្រាប់ធ្វើដំណើរ ស្នាក់នៅរបស់ចៅក្រម ក្រឡាបញ្ជី ក្នុងការពិនិត្យភស្តុតាង ស្រាវជ្រាវអង្គហេតុ សាកសួរសាក្សី ដែលប្រព្រឹត្តនៅក្រៅតុលាការ។[36]

**ប្រាក់ប្រដាប់ក្តីភាគី៖** ជាប្រភេទមួយនៃប្រាក់ប្រដាប់ក្តីដែលកំណត់ដោយតុលាការដែល គិតពិចារណានូវលក្ខណៈនៃរឿងក្តី ឬ លទ្ធផលទ្រព្យធនរបស់ភាគីជាអាទិ៍ សម្រាប់ថ្លៃធ្វើលិខិត បណ្តឹង លិខិតពាក្យសុំ សោហ៊ុយធ្វើដំណើរ ឬសោហ៊ុយផ្សេងៗ។[37]

## ៣.២. បន្ទុកនៃប្រាក់ប្រដាប់ក្តី

បន្ទុកនៃប្រាក់ប្រដាប់ក្តីត្រូវធ្លាក់ទៅលើ៖

- ភាគីចាញ់ក្តី ប៉ុន្តែបើចាញ់មួយភាគ តុលាការត្រូវសម្រេចដោយឆន្ទានុសិទ្ធិ
- ភាគីឈ្នះក្តី បើភាគីនោះប្រព្រឹត្តសកម្មភាពមិនចាំបាច់ ឬធ្វើឲ្យនីតិវិធីយឺតយ៉ាវ
- សហបណ្តឹង ត្រូវទទួលបន្ទុកស្មើគ្នា ឬដោយសាមគ្គី ប៉ុន្តែអាចឲ្យភាគីសហបណ្តឹងទទួល បន្ទុកច្រើនជាង សហបណ្តឹងផ្សេងទៀតបាន ករណីដែលភាគីសហបណ្តឹងនោះប្រព្រឹត្ត សកម្មភាពដែលមិនចាំបាច់
- អ្នកតំណាងដែលច្បាប់កំណត់ អ្នកតំណាងដោយអាណត្តិ ឬក្រឡាបញ្ជីបានធ្វើឲ្យ ចំនួនទឹកប្រាក់ប្រដាប់ក្តីដែលគ្មានប្រយោជន៍កើតឡើង ដោយចេតនា ឬដោយមាន

[34] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦១ កថាខណ្ឌទី១។

[35] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦១ កថាខណ្ឌទី៧។

[36] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦២ កថាខណ្ឌទី២។

[37] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦៣។

កំហុសធ្ងន់ធ្ងររបស់ខ្លួន ត្រូវសងប្រាក់ប្រដាប់ក្តីនោះវិញ ដោយដីកាសម្រេចតាម ពាក្យសុំ ឬដោយឆន្ទានុសិទ្ធិ។[38]

ក្នុងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលមានតំណាងអយ្យការជាភាគី ប្រាក់ប្រដាប់ក្តីដែលតំណាងអយ្យការត្រូវទទួលបន្ទុក ជាបន្ទុករបស់រដ្ឋ។[39] តំណាងអយ្យការក៏ជាអ្នកចូលរួមជាភាគីក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែរ ដើម្បីសម្រេចនូវផលប្រយោជន៍សាធារណៈក្នុងការបង្កើត ឬ ការបញ្ជាក់នូវទំនាក់ទំនងឋានៈបុគ្គល ក្នុងករណីដែលគ្មានភាគីនៃទំនាក់ទំនងឋានៈបុគ្គល ដូចច្នេះទោះជាតំណាងអយ្យការបានចាញ់ក្តីក៏ដោយ ក៏មិនគួរឲ្យតំណាងអយ្យការនោះទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីដោយផ្ទាល់ខ្លួនដែរ។

## ផ្នែកទី៤៖ ការចាត់ចែងពាក្យបណ្តឹង

ពេលមានវិវាទ ឬ ហេតុដែលឈានដល់ការប្តឹងលុបចោលអាពាហ៍ពិពាហ៍កើតឡើង ភាគីដើមចោទនឹងធ្វើការដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច ក្នុងបំណងទាមទារកម្មវត្ថុពីចុងចម្លើយ ដែលទាក់ទងនឹងវិវាទនោះ។ ការណ៍នៃការទទួលពាក្យបណ្តឹង ការពិនិត្យពាក្យបណ្តឹង ការបញ្ជូនពាក្យបណ្តឹង និងការកំណត់កាលបរិច្ឆេទត្រៀមសម្រាប់ទាញហេតុផលផ្ទាល់មាត់មិនមានបញ្ញត្តិពិសេសសម្រាប់អនុវត្តក្នុងនីតិវិធីបណ្តឹងទាក់ទងឋានៈបុគ្គលទេ ហេតុនេះការអនុវត្តត្រូវយកតាមវិធានដែលមានបញ្ញត្តិក្នុងនីតិវិធីបណ្តឹងធម្មតា ពោលគឺក្រមនីតិវិធីរដ្ឋប្បវេណី។

### ៤.១. ការទទួលពាក្យបណ្តឹង

ពាក្យបណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ជាលាយល័ក្ខណ៍អក្សរ ដែលដាក់ដោយដើមចោទ ទៅតុលាការ ត្រូវបានក្រឡាបញ្ជីដែលទទួលពាក្យបណ្តឹងនោះ បោះត្រា ដែលមានចុះថ្ងៃ ខែ ឆ្នាំទទួលពាក្យបណ្តឹង ដើម្បីបញ្ជាក់ពីពេលវេលានៃការដាក់ពាក្យបណ្តឹងនោះឲ្យបានច្បាស់ ហើយ ធ្វើសំណុំរឿងនៃបណ្តឹងនោះ ដោយបន្ថែមក្រប ព្រមទាំងចុះលេខបណ្តឹង។ បន្ទាប់មកក្រឡាបញ្ជីត្រូវបែងចែកសំណុំរឿងនៃបណ្តឹងនោះ ទៅឲ្យចៅក្រមដែលត្រូវទទួលបន្ទុករឿងក្តីនោះ តាមលំដាប់នៃការបែងចែករឿងក្តីដែលកំណត់ប្រចាំឆ្នាំ ដោយប្រធានតុលាការ។ ករណីចៅក្រមទទួលបន្ទុកមានធុរៈ មិនអាចចាត់ការបណ្តឹងនោះបានទេ ត្រូវបែងចែកទៅឲ្យចៅក្រមផ្សេងទៀត ទៅតាមលំដាប់សម្រាប់ជំនួស ដែលត្រូវបានកំណត់ជាមុន ដោយប្រធានតុលាការ។[40] ការបែងចែករឿងក្តី

[38] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦៩។

[39] ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល,លេខ នស/រកម/០៦១០/០០៨,៨ មិថុនា ២០១០,មាត្រា១០។

[40] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៦។

នៅតុលាការមួយ និង លំដាប់សម្រាប់ជំនួស មិនអាចត្រូវប្តូរក្នុងឆ្នាំនោះបានឡើយ លុះត្រាតែមានមូលហេតុដែលពុំអាចជៀសវៀងបាន។ មូលហេតុនោះរួមមានៈ ចៅក្រមណាម្នាក់មានការងារច្រើនពេក ឬ ករណីចៅ ក្រមត្រូវឈប់ ឬប្តូរទៅតុលាការផ្សេង ឬ ករណីដែលចៅក្រមបន្តមានធុរៈដោយសារហេតុផលដូច ជាត្រូវឈប់សម្រាកក្នុងរយៈពេលវែងជាអាទិ៍។ ការផ្លាស់ប្តូរចំពោះករណីនេះត្រូវកំណត់ដោយដីកា សម្រេចរបស់ប្រធានតុលាការ។

## ៤.២. ការពិនិត្យពាក្យបណ្តឹង

ក្រោយទទួលបានពាក្យបណ្តឹង ចៅក្រមទទួលបន្ទុកដែលបានទទួលការចាត់តាំង ត្រូវធ្វើការពិនិត្យ អំពីភាពសមស្រប ឬមិនសមស្របនៃពាក្យបណ្តឹង ដោយពិនិត្យលើលក្ខខណ្ឌទម្រង់ (ចំណុចដែល ត្រូវសរសេរក្នុងពាក្យបណ្តឹង) និង ពន្ធដាក់ពាក្យបណ្តឹង។

បើពិនិត្យឃើញថា មានការខ្វះខាតចំណុចដែលចាំបាច់ត្រូវសរសេរក្នុងពាក្យបណ្តឹង ឬ មិនបានបង់ពន្ធដាក់ពាក្យសុំ ចៅក្រមក្រមត្រូវចេញដីកាបង្គាប់ឲ្យកែតម្រូវ ដោយមានកំណត់អំឡុងពេលសមរម្យមួយ។ ប្រសិនបើដើមចោទមិនបានធ្វើការកែតម្រូវក្នុងអំឡុងពេលដែលបានកំណត់ទេ តុលាការត្រូវលើកចោលពាក្យបណ្តឹងដោយដីកាសម្រេច។ [41] បើមានការមិនពេញចិត្តនឹងដីកាសម្រេចនេះ ដើមចោទអាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍បាន។

តុលាការអាចបង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ សម្រាប់កោះហៅភាគីដោយកំណត់អំឡុងពេលសមរម្យ។ បើមិនបានបង់ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធនេះទេ តុលាការអាចចេញដីកាសម្រេចលើកបណ្តឹងនោះចោលដោយគ្មានការតវ៉ាពីចុងចម្លើយ តែដីកានេះអាចប្តឹងជំទាស់បាន។[42]

## ៤.៣. ការបញ្ជូនពាក្យបណ្តឹង

ក្រោយការពិនិត្យពាក្យបណ្តឹង បើតុលាការទទួលស្គាល់ថា ពាក្យបណ្តឹងនោះត្រឹមត្រូវតាមទម្រង់ ហើយ ក្រឡាបញ្ជីត្រូវទទួលបន្ទុកការបញ្ជូនពាក្យបណ្តឹងនោះ[43] ទៅឲ្យចុងចម្លើយ។

ការបញ្ជូនមានច្រើនប្រភេទដូចជាៈ

---

[41] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៧៨។

[42] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៨២។

[43] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៨៦។

**ការបញ្ជូនដោយប្រគល់ ៖** ការបញ្ជូនដោយប្រគល់ត្រូវធ្វើឡើងដោយវិធីប្រគល់នូវឯកសារទៅឲ្យ ជនដែលត្រូវទទួលការបញ្ជូននោះ។[44] ករណីអ្នកទទួលការបញ្ជូនមិនចេះអក្សរ មន្ត្រីទទួលបន្ទុក កិច្ចការបញ្ជូន គប្បីពន្យល់នូវខ្លឹមសារនៃឯកសារនៅពេលប្រគល់។

**ការបញ្ជូនដោយការជួបប្រទះ ៖** បើជនដែលត្រូវទទួលការបញ្ជូន ពុំច្បាស់ថាមានលំនៅឋាន ឬ ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការនៅក្នុងប្រទេសកម្ពុជាទេ ការបញ្ជូនអាចធ្វើបាននៅទីកន្លែងដែលជួបជននោះ លើកលែងតែក្នុងករណីដែលមានការជូនដំណឹងអំពីទីកន្លែងដែល ត្រូវធ្វើការបញ្ជូន នោះមន្ត្រីទទួលបន្ទុកការបញ្ជូន ត្រូវបញ្ជូនទៅកាន់ទីកន្លែងដែលបានជូនដំណឹងនោះ។[45] ម្យ៉ាងទៀតទោះបីមានលំនៅឋានទីសំណាក់ ទីកន្លែងអាជីវកម្ម ឬមានការជូនដំណឹងអំពីទីកន្លែងដែលត្រូវទទួលការបញ្ជូនក៏ដោយ មន្ត្រីទទួលបន្ទុកការបញ្ជូនក៏អាចបញ្ជូននៅទីកន្លែងដែលបានជួបប្រទះជននោះបានដែរ បើជននោះមិនប្រកែកចំពោះការទទួលការបញ្ជូននោះទេ។

**ការបញ្ជូនដោយបង្គ្រប់កិច្ច ៖** ក្នុងករណីមិនជួបជនដែលត្រូវបានទទួលការបញ្ជូននៅទីកន្លែងដែល ត្រូវទទួលការបញ្ជូនទេ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន អាចប្រគល់ឯកសារនោះទៅអ្នកបម្រើ ឬ បុគ្គលផ្សេងទៀតធ្វើការនៅទីនោះ ដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារ។[46] បុគ្គលដែលចាត់ទុកថាមានការយល់ដឹងសមរម្យត្រង់ចំណុចនេះសំដៅលើ អ្នកដែលយល់អំពីអត្ថន័យនៃ ការបញ្ជូន សារៈសំខាន់នៃការបញ្ជូន និងមានសមត្ថភាពអាចយកឯកសារនោះទៅប្រគល់ឲ្យជន ដែលត្រូវទទួលការបញ្ជូន។

**ការបញ្ជូនដោយទុកចោល ៖** ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ឬ ជនដែលត្រូវទទួលការបញ្ជូនដោយបង្គ្រប់កិច្ចតាមមាត្រា ២៥២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនទទួលការបញ្ជូនដោយគ្មានមូលហេតុត្រឹមត្រូវទេ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន អាចទុកឯកសារដែលជាកម្មវត្ថុនៃការបញ្ជូននោះចោលនៅទីកន្លែងនោះបាន ដែលការអនុវត្តបែបនេះមានអានុភាព ជាការបញ្ជូន និងត្រូវបានទទួលស្គាល់ដោយច្បាប់ជាធរមាន។

**ការបញ្ជូនទៅបរទេស ៖** បើជនដែលត្រូវទទួលការបញ្ជូនមានទីលំនៅនៅបរទេស ហើយពុំមានទីសំណាក់ កន្លែងអាជីវកម្ម ឬទីស្នាក់ការដែលអាចបញ្ជូនបាន នៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ការបញ្ជូនប្រភេទនេះគឺត្រូវបញ្ជូនទៅប្រទេសរបស់ជននោះតាម២របៀបគឺ

---

[44] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៤៧។

[45] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥១។

[46] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥២ កថាខណ្ឌទី១។

ករណីជនដែលត្រូវ ទទួលការបញ្ជូនជាជនជាតិបរទេស គប្បីបញ្ជូនដោយប្រគល់ឯកសារឲ្យក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះ ជាអ្នកអនុវត្តកិច្ចការបញ្ជូន។

ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិខ្មែរតែរស់នៅបរទេស គប្បីបញ្ជូនដោយឯកអគ្គរាជទូត ភារធារី ឬកុងស៊ុលរបស់ប្រទេសកម្ពុជាប្រចាំប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន។[47] ទោះបីប្រើវិធីណាមួយក្នុងចំណោមវិធីទាំងពីរនេះក៏ដោយ មុននឹងសម្រេចបញ្ជូនឲ្យស្ថាប័នណាជាអ្នកមានតួនាទីក្នុងការបញ្ជូន តុលាការគប្បីពិនិត្យមើល អនុសញ្ញា សន្ធិសញ្ញា ឬកិច្ចព្រមព្រៀងរវាងប្រទេសកម្ពុជា ជាមួយនឹងប្រទេសនោះ ឬការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ជៀសវាងការអនុវត្តនីតិវិធីនៃការបញ្ជូនខុសពីការកំណត់ក្នុងសន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងនោះ។ ចំពោះជនបរទេស ដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា វិធីនៃការបញ្ជូនត្រូវអនុវត្តដូចការ បញ្ជូនចំពោះជនជាតិខ្មែរដែរ។

**ការបញ្ជូនតាមការផ្សាយជាសាធារណៈ ៖** ដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបានគឺ ត្រូវគោរពនូវលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងអស់ ក្រឡាបញ្ជីអាចធ្វើការផ្សាយជា សាធារណៈ និងបន្ទាប់ពីមានការអនុញ្ញាតពីតុលាការ។ ជាគោលការណ៍ ដើម្បីអាចធ្វើការបញ្ជូនជាសារធារណៈបាន គឺត្រូវមានពាក្យសុំពីភាគីដែលសុំឲ្យតុលាការធ្វើការបញ្ជូនតាមរយៈ ការផ្សាយជាសាធារណៈ និងបន្ទាប់ពីមានការអនុញ្ញាតពីតុលាការ។ តែដើម្បីជៀសវាងការយឺតយ៉ាវតុលាការក៏អាច បង្គាប់ឲ្យក្រឡាបញ្ជី ធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ដោយឆន្ទានុសិទ្ធិបានទោះបីគ្មាន ពាក្យសុំពីភាគីក៏ដោយ។[48]

ដើម្បីធ្វើការបញ្ជូនពាក្យបណ្តឹង ត្រូវទាមទារឲ្យដើមចោទត្រៀមនូវឯកសារចម្លងនៃពាក្យបណ្តឹងទៅតាមចំនួនដែលត្រូវការ តាមចំនួននៃចុងចម្លើយ ហើយបញ្ជូនឯកសាសរសេរចម្លងនៃពាក្យបណ្តឹងនោះទៅឲ្យ ចុងចម្លើយចំណែកឯកសារដើម នៃពាក្យបណ្តឹងត្រូវរក្សាទុកដោយតុលាការ។

ករណីមិនអាចបញ្ជូនបានដោយហេតុ អាសយដ្ឋានរបស់ចុងចម្លើយដែលសរសេរក្នុងពាក្យបណ្តឹងនោះមិនត្រឹមត្រូវ ឬ មិនបានបង់សោហ៊ុយចាំបាច់ជាមុនសម្រាប់ធ្វើការបញ្ជូន តុលាការត្រូវបង្គាប់ឲ្យធ្វើការកែតម្រូវ ដោយកំណត់អំឡុងពេលដើម្បីកែតម្រូវ ដូចក្នុងករណីដែលមានកង្វះក្នុងការសរសេរក្នុងពាក្យបណ្តឹងដែរ។

[47] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥៣។

[48] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥៦។

ទោះបីជាដើមចោទបានដាក់ពាក្យបណ្ដឹងទៅតុលាការក៏ដោយ ទំនាក់ទំនងគតិយុត្តនឹងកើតមានឡើងរវាងតុលាការ និង ដើមចោទប៉ុណ្ណោះ រហូតដល់ពេលដែលពាក្យបណ្ដឹងនោះត្រូវបានបញ្ជូនទៅចុងចម្លើយ។ តាមរយៈការបញ្ជូនពាក្យបណ្ដឹងទៅចុងចម្លើយ ចុងចម្លើយនឹងក្លាយជាប្រធាននៃនីតិវិធីនៃបណ្ដឹងនោះ ហើយទំនាក់ទំនងគតិយុត្តរវាងភាគីទាំងបី គឺតុលាការ ដើមចោទ និង ចុងចម្លើយ នឹងកើតមានឡើងពីពេលនោះ។ ក្នុងន័យនេះការដាក់ពាក្យបណ្ដឹង ត្រូវបានសម្រេចដោយការបញ្ជូនពាក្យបណ្ដឹងនោះទៅឲ្យចុងចម្លើយ។

## ៤.៤. ការកំណត់កាលបរិច្ឆេទត្រៀមសម្រាប់ទាញហេតុផលផ្ទាល់មាត់

ពេលដែលបណ្ដឹងបានដាក់ តុលាការត្រូវធ្វើការកំណត់យ៉ាងឆាប់រហ័សនូវកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលជាកាលបរិច្ឆេទលើកដំបូងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ អំឡុងពេល ៣០ថ្ងៃ គិតពីពេលដែលពាក្យបណ្ដឹងត្រូវបានដាក់ និងកោះហៅគូភាគីចូលសវនាការតាមការបរិច្ឆេទនេះ។ [49] ក្នុងទិដ្ឋភាពិតនៃការអនុវត្តជាក់ស្ដែង ក្រោយពីបានពិនិត្យ ហើយបានទទួលពាក្យបណ្ដឹង តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីនៃការទាញហេតុផលលើកដំបូង ហើយត្រូវធ្វើការបញ្ជូនពាក្យបណ្ដឹង ព្រមជាមួយនឹងដីកាកោះហៅចុងចម្លើយឲ្យមកតុលាការ តាមកាលបរិច្ឆេទកំណត់នេះ។ តុលាការនឹងមិនអាចធ្វើការបញ្ជូនពាក្យបណ្ដឹង ព្រមគ្នានឹងដីកាកោះហៅចុងចម្លើយស្ដីពីកាលបរិច្ឆេទលើកដំបូងបានទេ ប្រសិនបើពុំបានបង់សោហ៊ុយជាមុន ហើយពាក្យបណ្ដឹងនោះនឹងត្រូវលើកចោលដោយតុលាការ។[50]

## ផ្នែកទី៥៖ នីតិវិធីនៃការត្រៀម និងទាញហេតុផលផ្ទាល់មាត់

ក្រោយពីបានបញ្ជូនពាក្យបណ្ដឹងហើយ ដោយមានការចូលរួមរបស់ភាគី តុលាការនឹងធ្វើការសម្រេចសេចក្ដីអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទារតាមផ្លូវបណ្ដឹង របស់ដើមចោទ និង ចេញសាលក្រម។ ការសម្រេចសេចក្ដីលើបណ្ដឹងនេះ ត្រូវធ្វើឡើងតាមវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់។

មុននឹងឈានដល់ការវិនិច្ឆ័យតាមរយៈនីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ តុលាការត្រូវអនុវត្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាមុនសិន ដើម្បីធានាឲ្យបាននូវការទាញហេតុផលដោយផ្ទាល់មាត់មួយដែលល្អិតល្អន់ និង ទទួលបាននូវសាលក្រមមួយដែលឆ្លើយតបទៅនឹងការពិតជាក់ស្ដែង។

[49] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៨០។

[50] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៨២។

## ៥.១. នីតិវិធីត្រៀមសម្រាប់ទាញហេតុផលផ្ទាល់មាត់

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីមួយដែលរៀបចំដើម្បីលើកកម្ពស់ និង សម្រួលដល់ការទាញហេតុផលដោយផ្ទាល់មាត់ ក្នុងគោលបំណងធ្វើការបំភ្លឺអំពីចំណុចវិវាទ រវាងភាគីដោយរៀបចំជាមុន នូវសេចក្តីអះអាងរបស់ភាគី និង ធ្វើការរៀបចំនូវភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទ ដែលត្រូវធ្វើការ ពិនិត្យ។ នៅក្នុងការទាញហេតុផលផ្ទាល់មាត់ ភាគីនីមួយៗតែងតែលើកឡើងនូវអង្គហេតុផ្សេងៗដែលខ្លួនយល់ថាមានប្រយោជន៍សម្រាប់ខ្លួនឯង ដោយមិនបានគិតថាអង្គហេតុនោះមាន ឬ គ្មានសារៈសំខាន់ចំពោះរឿងក្តីនោះទេ។ ស្របគ្នាដែរ ភាគីម្ខាងៗតែងតែតវ៉ាចំពោះការលើកឡើងនូវ អង្គហេតុរបស់ភាគីម្ខាងទៀត ហើយតែងតែព្យាយាមដាក់ភស្តុតាងទាំងឡាយដែលខ្លួនគិតថាមានប្រយោជន៍សម្រាប់ខ្លួនឯង។ ជាលទ្ធផល ការធ្វើបែបនេះនឹងនាំឲ្យការជម្រះក្តីមានភាពស្មុគស្មាញ ព្រមទាំងអូសបន្លាយដោយឥតប្រយោជន៍ និង ធ្វើឲ្យលំបាកក្នុងការស្វែងរកការពិត។ ដូច្នេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា នៅមុនការជម្រះក្តីដោយការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវរៀបចំនីតិវិធីសម្រាប់ការត្រៀមទាញហេតុផល ដើម្បីឲ្យការទាញហេតុផលដោយផ្ទាល់មាត់ គ្មានភាពស្មុគស្មាញ គ្មានអូសបន្លាយពេលវេលាដោយឥតប្រយោជន៍ និង ងាយស្រួលក្នុងការស្វែងរកការពិត ដើម្បីឆ្លើយតបនឹងការទទួលខុសត្រូវរបស់តុលាការ ដែលច្បាប់បានបញ្ញត្តិដោយតម្រូវឲ្យតុលាការត្រូវប្រឹងប្រែង ដើម្បីរ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឲ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌និងឆាប់រហ័ស[51]។

អវត្តមានចុងចម្លើយក្នុងនីតិវិធីត្រៀមទាញហេតុផលនេះ មិនអាចចាត់ទុកថាជាការសារភាពទេ ពោលគឺតុលាការទុកសិទ្ធិឲ្យចុងចម្លើយក្នុងការចូលរួម ឬ មិនចូលរួមក្នុងនីតិវិធីត្រៀមទាញហេតុផលនេះ ហើយគ្រប់ការអះអាងអង្គហេតុរបស់ភាគី ទោះបីជាការសារភាព ឬ មិនសារភាពក៏តុលាការធ្វើការទទួលស្គាល់អង្គហេតុឲ្យស្របទៅនឹងការពិតជាក់ស្តែង ដោយពឹងផ្អែកលើគោលការណ៍ជំនឿទុកចិត្តដោយសេរីរបស់ខ្លួន។

## ៥.២. នីតិវិធីទាញហេតុផលផ្ទាល់មាត់

នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគីនូវអង្គហេតុដែលនឹងត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទ នៃការទាញហេតុផលផ្ទាល់មាត់។[52] ក្រៅពីការបញ្ជាក់អំពីអង្គហេតុ និងភស្តុតាងដែលនឹងត្រូវធ្វើការពិនិត្យ តុលាការ

[51] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៩។

[52] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១០៧។

ត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីឲ្យមកចូលរួមតាមកាលបរិច្ឆេទដែលបានកំណត់នោះ។[53]

ការទាញហេតុផលផ្ទាល់មាត់ គឺជាទម្រង់មួយនៃការជម្រះក្តីដែលក្នុងនោះ សកម្មភាពរបស់តុលាការ និងសកម្មភាពរបស់ភាគី ចំពោះការជម្រះក្តីត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍នៅសាលសវនាការដែលភាគីទាំងសងខាងអាចមានវត្តមានតាមកាលបរិច្ឆេទ។

### ៥.២.១. ការជម្រះក្តីក្នុងការទាញហេតុផលផ្ទាល់មាត់

ការជម្រះក្តីនៃបណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ មិនត្រូវធ្វើជាសាធារណៈឡើយ។ ប៉ុន្តែបើតុលាការយល់ឃើញថាសមរម្យ អាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ឬ អនុញ្ញាតឲ្យជនណាដែលតុលាការយល់ឃើញថាសមរម្យចូលស្តាប់ជាអ្នកសង្កេតការណ៍ បានតាមឆន្ទានុសិទ្ធ។[54]

#### ក.សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផលផ្ទាល់មាត់

ការត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ដែលបានធ្វើឡើងនៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានលក្ខណៈប្រហាក់ប្រហែលទៅនឹង ការហាត់សមធ្វើការទាញហេតុផលផ្ទាល់មាត់ដែរ តែមិនអាចយកវាមកជំនួសឲ្យការទាញហេតុផលផ្ទាល់ពិតប្រាកដបានទេ។

នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាបឋមគូភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលក្នុងនោះត្រូវបញ្ជាក់ឲ្យច្បាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាងដែលនឹងត្រូវធ្វើនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់[55] ពោលគឺត្រូវបញ្ជាក់ពីចំណុចវិវាទឲ្យបានច្បាស់។

#### ក. ការដាក់មធ្យោបាយតទល់ ឬការពារខ្លួន

ក្នុងបណ្តឹងលុបចោលអាពាហ៍ពិពាហ៍នេះ មិនមានបញ្ញត្តិហាមឃាត់ការដាក់មធ្យោបាយតទល់ពីដើមចោទ ឬមធ្យោបាយការពារខ្លួនពីចុងចម្លើយទេ។ ហេតុនេះភាគីអាចធ្វើការនាំយកឬប្រមូលនូវរាល់ ភស្តុតាង ឯកសារពាក់ព័ន្ធទាំងឡាយ ក៏ដូចជាស្នើសុំឲ្យធ្វើការសាកសួរសាក្សីដែលពាក់ព័ន្ធក្នុងបណ្តឹងដើម្បីឲ្យតុលាការត្រួតពិនិត្យ។ ក្នុងបណ្តឹងនេះ សិទ្ធិរបស់គូភាគីក្នុងការដាក់

[53] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១១៣។

[54] ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល,លេខ នស/រកម/០៦១០/០០៨,៨ មិថុនា ២០១០,មាត្រា១៦។

[55] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១១៦។

នូវមធ្យោបាយតទល់ ឬការពារខ្លួនត្រូវបានផ្តល់នូវលក្ខខណ្ឌកាន់តែប្រសើរ ពោលគឺទោះបីការដាក់មធ្យោបាយតទល់ ឬការពារខ្លួនយឺត ឬមិនត្រូវនឹងពេលសមរម្យដែលបានកំណត់ក្តី តុលាការពុំអាចចេញដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬការពារខ្លួនដែលបានដាក់យឺតយ៉ាវទេ[56] ពីព្រោះបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទាមទារឲ្យគូភាគីបង្ហាញនូវតម្រុយ ឬឯកសារភស្តុតាងជាក់លាក់ដើម្បីទុកលទ្ធភាពបន្ថែមឲ្យតុលាការពិចារណា និងស្រាវជ្រាវបន្ថែម ដើម្បីស្វែងរកការពិតនៃរឿង។

ដើមចោទត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីមូលហេតុនៃការដាក់សំណូមពរ ពោលគឺមធ្យោបាយតទល់។ រីឯចុងចោទត្រូវធ្វើសេចក្តីថ្លែងការណ៍ ចំពោះមូលហេតុនៃការឆ្លើយតបរបស់ខ្លួន ពោលគឺមធ្យោបាយការពារខ្លួន។ ប៉ុន្តែសិទ្ធិនេះមិនត្រូវបានទទួលស្គាល់ភ្លាមៗនោះទេ គឺដើមចោទត្រូវអះអាងអំពីអង្គហេតុដែលត្រូវនឹងលក្ខខណ្ឌគតិយុត្ត ដែលមានអានុភាពបង្កើតឲ្យមានសិទ្ធិ។

បន្ទាប់ពីគូភាគីបានដាក់មធ្យោបាយតទល់ ឬការពារខ្លួនហើយ តុលាការត្រូវធ្វើការសម្រេចដោយយោងលើគោលការណ៍ស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និងបញ្ចប់ការទាញហេតុផលផ្ទាល់មាត់។

### ៥.២.២. ការបញ្ចប់ការទាញហេតុផលផ្ទាល់មាត់

ក្រោយពេលស្តាប់ការអះអាងរបស់ភាគី តុលាការពិនិត្យលើសំណុំរឿង ឯកសារពាក់ព័ន្ធដោយផ្អែក លើការស្រាវជ្រាវស្វែងរកការពិត ហើយចេញសាលក្រមលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការ ទាមទាររបស់ដើមចោទ ដោយបញ្ចប់នូវការទាញហេតុផលផ្ទាល់មាត់ និងចេញសាលក្រមចុងក្រោយ។ នៅមុនពេលបញ្ចប់ តុលាការអាចអនុញ្ញាតឲ្យភាគីទាញហេតុផលចុងក្រោយបានវាជាឱកាសដែលភាគីនីមួយៗ អាចលើកឡើងនូវមតិចុងក្រោយរបស់ខ្លួនពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការទាមទារ។

ក្រោយពេលបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ហើយបើយល់ថាចាំបាច់តុលាការអាចបើកឲ្យមានការទាញហេតុផលផ្ទាល់មាត់ដែលត្រូវបានបញ្ចប់ហើយនោះសាជាថ្មីឡើងវិញបានមុនពេលចេញសាលក្រមចុងក្រោយ។[57]ម្យ៉ាងទៀតបើនៅក្នុងដំណាក់កាលនីតិវិធីទាញហេតុផល មានលេចចេញនូវអង្គហេតុថ្មីដែលរាំងស្ទះ ឬបង្អាក់ក្នុងការស្វែងរកការពិតដែលចាំបាច់ត្រូវសាកសួរភាគី ឬស្រាវជ្រាវបន្ថែម ច្បាប់បានផ្តល់ការអនុញ្ញាតឲ្យតុលាការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលម្តងទៀតបាន បើតុលាការបញ្ចប់ការទាញហេតុផលក្នុងកាលៈទេសៈបែបនេះ វាអាចផ្ទុយនឹងក្របខ័ណ្ឌយុត្តិធម៌ ប៉ះពាល់ដល់ប្រយោជន៍ជនដែលទទួលនូវអានុភាពនៃសាលក្រម។

[56] ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល,លេខ នស/រកម/០៦១០/០០៨,៨ មិថុនា ២០១០,មាត្រា១៣។

[57] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ១៨០ កថាខណ្ឌទី៣។

# ផ្នែកទី៦៖ សេចក្តីសម្រេចលើបណ្តឹង

## ៦.១. សាលក្រមចំពោះមុខ

តុលាការចេញសាលក្រមលើបណ្តឹង ដោយសាលក្រមរបស់តុលាការជាន់ទាបឬសាលដីការបស់តុលាការជាន់ខ្ពស់ ដែលការណ៍នេះខុសពីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ដែលតុលាការចេញសេចក្តីដោយដីកាសម្រេច។[58]

ក្នុងនីតិវិធីបណ្តឹងនេះ តុលាការមិនអនុញ្ញាតឲ្យយកគោលការណ៍នៃការចេញសាលក្រមកំបាំងមុខមកអនុវត្តទេ។[59] មុនចេញសេចក្តីសម្រេច តុលាការចាំបាច់ត្រូវមានវត្តមានរបស់គូភាគីក្នុងអង្គសវនាការដើម្បីធានានូវសិទ្ធិក្នុងការបញ្ចេញមតិយោបល់ សំណូមពរ ក៏ដូចជាដំណាក់កាលចុងក្រោយនៃការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីការទាមទាររបស់ខ្លួន ចំពោះមុខចៅក្រមជំនុំជម្រះ ហើយតុលាការក៏អាចពិចារណាបន្ថែមទៀតទៅលើការអះអាងនោះ ដើម្បីចេញសាលក្រមចុងក្រោយឲ្យមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ដល់ភាគីផ្អែកលើការស្រាវជ្រាវ និងការពិតជាក់ស្តែង។

ជាគោលការណ៍ ចំពោះសេចក្តីសម្រេចនៅក្នុងនីតិវិធីបណ្តឹងនីមួយៗ គឺបានកំណត់ពីការធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលជាវិធានធានានូវសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីច្រើនថ្នាក់របស់ភាគី។ តុលាការជាន់ខ្ពស់អាចនឹងពិនិត្យមើលនូវសេចក្តីសម្រេចរបស់ តុលាការថ្នាក់ក្រោមបានតាមពាក្យបណ្តឹងរបស់ភាគីម្ខាងដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចនោះ បើសេចក្តីសម្រេចតុលាការជាន់ទាបមិនត្រឹមត្រូវ តុលាការជាន់ខ្ពស់អាចធ្វើការកែប្រែ ឬលុបចោលនូវសេចក្តីសម្រេចនោះ ហើយចេញសេចក្តីសម្រេចថ្មី។

## ៦.២. បណ្តឹងឧបាស្រ័យ

ការប្តឹងឧបាស្រ័យនេះ មានលក្ខណៈដូចនីតិវិធីបណ្តឹងរដ្ឋប្បវេណីដែរ គឺធ្វើតាមរយៈបណ្តឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍ ដើម្បីទទួលចំណាត់ការបន្តលើសេចក្តីវិនិច្ឆ័យរបស់សាលាដំបូង។ បណ្តឹងនេះត្រូវធ្វើក្នុងរយៈពេល ១(មួយ) ខែ[60] គិតពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមទៅកាន់សាលាដំបូងដែលចេញសាលក្រមនោះ។

---

[58] ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល,លេខ នស/រកម/០៦១០/០០៨,៨ មិថុនា ២០១០,មាត្រា៣។

[59] ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល,លេខ នស/រកម/០៦១០/០០៨,៨ មិថុនា ២០១០,មាត្រា១៣ កថាខណ្ឌទី១។

[60] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៦៤ កថាខណ្ឌទី១។

បើតុលាការចេញសាលក្រមទទួលស្គាល់ការទាមទាររបស់ដើមចោទនៅក្នុងបណ្ដឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ តុលាការត្រូវធ្វើការសម្រេចសេចក្ដីអំពីការកំណត់អ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិ បើមានពាក្យសុំរបស់ភាគី ត្រូវធ្វើការសម្រេចសេចក្ដីអំពីការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ឬការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ។[61]

[61] ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល,លេខ នស/រកម/០៦១០/០០៨,៨ មិថុនា ២០១០,មាត្រា២២។

## ជំពូកទី៣៖ អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍ មិនមានអានុភាពប្រតិសកម្មទេ[62] មានន័យថា ការលុបចោលអាពាហ៍ពិពាហ៍មិនមានអានុភាពទៅលើអតីតកាល គឺមានអានុភាពរំលាយអាពាហ៍ពិពាហ៍ ឆ្ពោះទៅរកថ្ងៃអនាគត ដែលគិតចាប់ពីថ្ងៃដែលតុលាការ បានប្រកាសសាលក្រមលើសេចក្ដីសម្រេចលុបចោលអាពាហ៍ពិពាហ៍នោះចូលជាស្ថាពរ។

### ផ្នែកទី១៖ អានុភាពចំពោះសំណងការខូចខាត

នៅពេលមានបណ្ដឹងកើតឡើង រមែងតែងមានភាគីទទួលរងនូវការខូចខាត ចំពោះបណ្ដឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ក៏មិនខុសគ្នាដែរ។ ភាគីដែលមិនបានដឹងអំពីមូលហេតុនៃការលុបចោល នៅពេលរៀបអាពាហ៍ពិពាហ៍ ប្រសិនបើទទួលបានទ្រព្យសម្បត្តិដោយការរៀបអាពាហ៍ពិពាហ៍ ត្រូវសងទ្រព្យសម្បត្តិនោះត្រឹមកម្រិតនៃផលប្រយោជន៍ទទួលបាន។[63]

ទ្រព្យសម្បត្តិដែលទទួលបានដោយការរៀបអាពាហ៍ពិពាហ៍រួមមាន៖

- ទ្រព្យសម្បត្តិដែលត្រូវបានធ្វើប្រទានកម្ម នៅពេល និងក្នុងពេលរៀបអាពាហ៍ពិពាហ៍
- ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈសន្តតិកម្ម និងអច្ច័យទាន
- ផលប្រយោជន៍ពីការធានារ៉ាប់រង ជាអាទិ៍។

ចំពោះភាគីដែលបានដឹងអំពីមូលហេតុនៃការលុបចោល នៅពេលរៀបអាពាហ៍ពិពាហ៍ត្រូវសងផលប្រយោជន៍ទាំងអស់ដែលបានទទួលដោយការរៀបអាពាហ៍ពិពាហ៍នោះ ហើយបើភាគីម្ខាងទៀតសុចរិត ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតនោះ។[64] សម្រាប់ផលប្រយោជន៍ទាំងអស់ដែលទទួលដោយការរៀបអាពាហ៍ពិពាហ៍ រួមមានទាំង ផលប្រយោជន៍លើទ្រព្យសម្បត្តិទាំងអស់ ដូចជាលំនៅ ថ្លៃចំណាយលើម្ហូបអាហារ និងការកម្សាន្ត ជាដើម។

[62] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៩៦៤ កថាខណ្ឌទី១។

[63] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៩៦៤ កថាខណ្ឌទី២។

[64] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៩៦៤ កថាខណ្ឌទី១។

# ផ្នែកទី២៖ អានុភាពចំពោះបុគ្គល

## ២.១. ចំពោះសាមីជន

អានុភាពនៃសាលក្រមលុបចោលអាពាហ៍ពិពាហ៍ អាចធ្វើឲ្យជីវិតគូមានការផ្លាស់ប្តូរទៅជាជីវិតនៅលីវម្តងទៀត ពោលគឺអាពាហ៍ពិពាហ៍ដែលមានអានុភាព ដែលអ្នកទាំងពីបានបង្កើតឡើងក្លាយទៅជាឥតបានការ។ ស្របពេលនោះផងដែរ ចំណងគតិយុត្តមួយចំនួនក៏ត្រូវបានរលាយ ដូចជា ករណីកិច្ចដែលប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក [65] និងនាមត្រកូលដែល សហព័ទ្ធម្ខាងបានប្តូរទៅប្រើនាមត្រកូលរបស់ សហព័ទ្ធម្ខាងទៀត [66] ។ ប៉ុន្តែក៏មានបញ្ហាមួយចំនួនតាមមកពីក្រោយ នៃការរំលាយអាពាហ៍ពិពាហ៍របស់ពួកគេផងដែរ នោះគឺបញ្ហាកូន និង ការបែងចែកទ្រព្យសម្បត្តិនេះឯង។

## ២.២. ចំពោះបុត្តភាព

នៅពេលដែលមានការរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ ប្រាកដជាមានការជះឥទ្ធិពលដល់កូន ដោយហេតុឪពុកម្តាយត្រូវបែកបាក់ ពោលគឺក្លាយជាអ្នកដទៃ។ ដូចនេះឪពុកម្តាយដែលត្រូវបានបែកគ្នា ត្រូវកំណត់យកភាគីណាម្ខាង ជាអ្នកមានអំណាចមេបាតាមការពិភាក្សារវាងភាគីទាំងសងខាង។ ប៉ុន្តែបើការពិភាក្សាមិនបានសម្រេច ឬពុំអាចពិភាក្សាបាន តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ។[67]

ប្រសិនបើអាពាហ៍ពិពាហ៍ត្រូវបានលុបចោលមុនពេលកំណើតរបស់កូន ម្តាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ។ ក្រោយពេលកំណើតកូន គេអាចកំណត់យកឪពុកជាអ្នកមានអំណាចមេបាបាន តាមការពិភាក្សារបស់ឪពុកម្តាយ។

ចំពោះទារកដែលទើបនឹងកើតគេត្រូវធ្វើការសន្មតបិតុភាពដោយ៖

- ទារកនៅក្នុងគភ៌ប្រពន្ធដែលមាននៅក្នុងចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្តី
- កូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ (មួយរយប៉ែតសិប)ថ្ងៃគិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើត ឬក្នុងអំឡុងពេល ៣០០ (បីរយ)ថ្ងៃ គិតចាប់ពីពេលដែលបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ត្រូវសន្មតថា មានគភ៌នៅក្នុងអំឡុងពេលមានអាពាហ៍ពិពាហ៍នោះ

[65] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៩៦៦។

[66] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៩៦៥។

[67] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ១០៣៧។

- ក្នុងករណីដែលស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀតផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៥០(អំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀតនៃក្រមនេះ បានបង្កើតកូន ប្រសិនបើមិនអាចកំណត់ឪពុករបស់កូននោះ ដោយយោងតាមបញ្ញតិនៃកថាខណ្ឌទី១ និងទី២ ខាងលើទេ ត្រូវសន្មតថា កូននោះជាកូនរបស់ប្តីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយ។[68]

ការកំណត់អ្នកមានអំណាចមេបា ឬ ការចាត់ចែងពាក់ព័ន្ធនឹងការបីបាច់រក្សាកូន ត្រូវធ្វើឡើងដោយគិតពិចារណាយ៉ាងសំខាន់ទៅលើសុខុមាលភាពរបស់កូន។ ដូច្នេះ តុលាការត្រូវសួរ និងគិតពិចារណានូវយោបល់ក្នុងការសម្រេចសេចក្តី ដោយមើលទៅតាមអាយុ ឬ ទៅតាមភាពយល់ដឹងរបស់កូននោះ។[69]

[68] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៩៨៨។

[69] ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល,លេខ នស/រកម/០៦១០/០០៨,៨ មិថុនា ២០១០,មាត្រា២២ កថាខណ្ឌទី៥។

# ផ្នែកទី៣៖ អានុភាពចំពោះទ្រព្យសម្បត្តិ

ក្រៅពីបញ្ហាសំណងការខូចខាត បញ្ហាចំពោះសាមីខ្លួន និង អំណាចមេបាលើបុត្តភាព មានបញ្ហាចោទមួយទៀតដែលអាចក្លាយជា ផលវិបាកក្រោយពេលមានការលុបចោលអាពាហ៍ពិពាហ៍ កើតឡើងគឺ ទ្រព្យសម្បត្តិ។

អាជ្ញាយុកាលនៃការលុបចោលអាពាហ៍ពិពាហ៍ធ្វើឲ្យកើតមាននូវសិទ្ធិ និង កាតព្វកិច្ចជាច្រើនរវាងសហព័ទ្ធដូចជា ការទទួលបានទ្រព្យ តាមរយៈកិច្ចមុធា និង កិច្ចមូលា ដែលកើតមានក្នុងពេលអាពាហ៍ពិពាហ៍ត្រូវបានលុបចោល។

សូមសិក្សា តាមរយៈរូបភាពសង្ខេបខាងក្រោម៖




បញ្ហាដែលអាចកើតមាន៖

- គតិ (បុត្តភាព)
- ទ្រព្យសកម្ម
  - កិច្ចមុធា (ស្នងមតិក ប្រទានកម្ម...)
  - កិច្ចមូលា (ទិញ)

- ទ្រព្យអកម្ម
  - កិច្ចមុធា ( ស្នងមតិក ប្រទានកម្ម)
  - កិច្ចមូលា (ទិញផ្ទាល់ ឬ តាមរូបភាពបង់រំលោះ)

## ៣.១. ចំពោះសកម្មទ្រព្យ

មិនថាមុន ឬ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ ក្រមរដ្ឋប្បវេណីខ្មែរបានផ្តល់សិទ្ធិសេរីភាពឲ្យសហព័ទ្ធទាំងសងខាងជ្រើសរើសនូវប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិដែលខ្លួនពេញចិត្ត។ ហេតុនេះនៅពេលដែលមានការបែកបាក់គ្នា ការបែងចែកទ្រព្យនឹងត្រូវអនុវត្តទៅតាមលក្ខខណ្ឌ ឬ បញ្ញត្តិដែលបានកំណត់ក្នុងប្រព័ន្ធនីមួយៗ ដែលប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធនោះ ចែកចេញជាពីរគឺ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និង ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់តាមច្បាប់។

### ៣.១.១. ប្រព័ន្ធទ្រព្យសម្បត្តិតាមវិធាននៃកិច្ចសន្យា

កិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធត្រូវបានធ្វើឡើង ដើម្បីទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យ សម្បត្តិ និង ដើម្បីបញ្ជាក់ឲ្យច្បាស់អំពីទំនាក់ទំនងសិទ្ធិ និង ករណីកិច្ចរបស់ប្តីប្រពន្ធ ពោលគឺសហព័ទ្ធទាំងសងខាងត្រូវបានផ្តល់លទ្ធភាព ដែលអាច កំណត់ដោយខ្លួនឯងនូវ សមាសភាពនៃទ្រព្យរួម វិធាននៃការគ្រប់គ្រង ព្រមទាំងការជម្រះបញ្ជី និងការបែងចែករបបមាតិកភណ្ឌគ្រួសារ។ ប៉ុន្តែបញ្ញត្តិនេះ មិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាម ទារអាហារកាតព្វកិច្ច និង ភាគបម្រុងបានឡើយ។ [70] កិច្ចសន្យាទ្រព្យប្តីប្រពន្ធ ត្រូវធ្វើជាលាយ លក្ខណ៍អក្សរ ហើយត្រូវចុះបញ្ជីឲ្យបានត្រឹមត្រូវ នៅក្រសួងយុត្តិធម៌ ដើម្បីអាចយកទៅតតាំង ជាមួយនឹងតតិយជនបាន។[71] ម្យ៉ាងទៀត ការជ្រើសរើសយកប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានេះ អាចផ្តល់ភាពងាយស្រួលដល់ស្ថាប័នតុលាការ ព្រមទាំងជៀសវាងនូវវិវាទវែងឆ្ងាយរវាងគូភាគី ពេលបែងចែកទ្រព្យសម្បត្តិក្រោយពេលអាពាហ៍ពិពាហ៍ត្រូវបានរំលាយដោយភាគីគ្រាន់តែអនុវត្តតាមបញ្ញត្តិដែលបានកំណត់ក្នុងកិច្ចសន្យានោះជាការស្រេច។

### ៣.១.២. ប្រព័ន្ធទ្រព្យសម្បត្តិកំណត់តាមច្បាប់

បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច បើសហព័ទ្ធទាំងសងខាងមិនបានសម្តែងឆន្ទៈថានឹង ជ្រើសរើសយក ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិណាមួយទេ នោះគេសន្មតថាពួកគេរើសយកប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ដោយស្វ័យប្រវត្តិ។ ក្នុងប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់នេះបាន បែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធជាពីរប្រភេទគឺ៖ ទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក។

#### ៣.១.២.១. ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដោយឡែក ជាទ្រព្យដែលសហព័ទ្ធម្ខាងមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ ទ្រព្យដែលទទួលបានតាមរយៈប្រទានកម្ម សន្តតិកម្ម អច្ច័យទាន និង ទ្រព្យដែលជាតម្លៃតបដែលទទួលបានតាមរយៈការចាត់ចែងទ្រព្យសម្បត្តិដោយឡែកផ្សេងទៀត។ [72] ជាការពិតណាស់ នៅពេលដែលជីវភាពអាពាហ៍ពិពាហ៍បន្តកាន់តែយូរទៅ មានករណីជាច្រើនដែលទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិដែលទទួលបានអំឡុងពេលរៀបអាពាហ៍

---

[70] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា៩៦៩ កថាខណ្ឌទី២។

[71] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៩៧០ កថាខណ្ឌទី១។

[72] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា៩៧២។

ពិពាហ៍ ក្លាយទៅជាមិនអាចបែងចែកច្បាស់លាស់ថា តើជាទ្រព្យផ្ទាល់ខ្លួន ឬ ជាទ្រព្យរួមដែលបណ្តាលឲ្យក្លាយទៅជាវិវាទនៅពេលមានការបែងចែកទ្រព្យកើតឡើង។ ជាដំណោះស្រាយភាគីគប្បីធ្វើជាបញ្ជីទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ដើម្បីបញ្ជាក់ឲ្យបានច្បាស់រវាងទ្រព្យដោយឡែក និងទ្រព្យរួម។ ទ្រព្យសម្បត្តិដោយឡែកនេះ មិនមែនជាកម្មវត្ថុនៃការបែងចែកនៅពេលដែកភាគីមានការបែកបាក់គ្នានោះទេ ព្រោះទ្រព្យប្រភេទនេះស្ថិតក្រោមការគ្រប់គ្រងរបស់សហព័ទ្ធតែម្ខាងដែលជាម្ចាស់កម្មសិទ្ធិប៉ុណ្ណោះ។ ហេតុនេះក្រោយពេលអាពាហ៍ពិពាហ៍ត្រូវបានលុបចោល ភាគីមិនអាចប្តឹងទាមទារឲ្យបែងចែកទ្រព្យសម្បត្តិដោយឡែករបស់ភាគីម្ខាងទៀតបានឡើយ។

### ៣.១.២.២. ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម ជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ថាជាទ្រព្យសម្បត្តិដោយឡែក។[73] សហព័ទ្ធទាំងសងខាង មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម តែការប្រើប្រាស់ទ្រព្យនោះ ត្រូវស្ថិតក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព។[74] ការចាត់ចែងទ្រព្យសម្បត្តិរួមដោយ យកទៅលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀត ដោយគ្មានការយល់ព្រមពីសហព័ទ្ធទាំងសងខាងមិនត្រូវបានអនុញ្ញាតឡើយ។ [75] នៅពេលមានការបែកបាក់កើតឡើង ទ្រព្យរួមនេះត្រូវធ្វើការបែងចែកដោយយុត្តិធម៌ ដោយផ្អែកតាមការពិភាក្សាព្រមព្រៀងរបស់សហព័ទ្ធទាំងសងខាង។ ករណីមានវិវាទក្នុងការបែងចែក ច្បាប់បានបញ្ញត្តិឲ្យចែកទ្រព្យនោះជាពីរភាគស្មើៗគ្នាទៅឲ្យសហព័ទ្ធនីមួយៗ។ ប៉ុន្តែបើមានការកើតទុក្ខមិនសុខចិត្តចំពោះការសម្រេចនេះ ភាគីម្ខាងអាចលើកលើកពីស្ថានភាពផ្សេងទៅកាន់តុលាការ ដើម្បីធ្វើការពិចារណាដូចជា ទំហំនៃការបរិច្ចាគ លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ ព្រមទាំងផលប្រយោជន៍កូនជាដើម។ គេហកិច្ចត្រូវចាត់ទុកមានតម្លៃស្មើនឹង ការងារដែលនៅក្រៅផ្ទះដែរ។[76]

## ៣.២. ចំពោះអកម្មទ្រព្យ

អកម្មទ្រព្យ គឺជាបំណុលដែលត្រូវបានគេយកមកបែងចែកផងដែរក្រោយពេលមាន ការលុបចោល អាពាហ៍ពិពាហ៍។ អកម្មទ្រព្យនេះត្រូវបានចែកជាពីរប្រភេទគឺ៖ អកម្មទ្រព្យដោយឡែក និងអកម្ម ទ្រព្យរួម។

---

[73] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា៩៧៣។

[74] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា៩៧៤។

[75] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា៩៧៦។

[76] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា៩៨០។

### ៣.២.១. អកម្មទ្រព្យដោយឡែក

អកម្មទ្រព្យដោយឡែក ឬ បំណុលផ្ទាល់ គឺជាបំណុលដែលសហព័ទ្ធម្ខាងបានជាប់ជំពាក់នាមុនពេលរៀបអាពាហ៍ពិពាហ៍។ ប៉ុន្តែក៏នៅមានករណីមួយចំនួនដែលសហព័ទ្ធម្ខាងបានជំពាក់ប្រាក់ក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ដែលបានឲ្យសហព័ទ្ធម្ខាងទៀតដឹងពីការជំពាក់នោះគឺជាការខ្ចីយកទៅប្រើប្រាស់ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ជាការខ្ចីយកទៅប្រើប្រាស់ ដែលឥតប្រយោជន៍ ដូច្នេះបំណុលនោះក៏មិនមានការពាក់ព័ន្ធជាមួយសហព័ទ្ធម្ខាងទៀតឲ្យទទួលខុសត្រូវចំពោះបំណុលនោះឡើយ។

ដូចគ្នានេះដែរ បំណុលដែលអាចចាត់ទុកថាជាបំណុលផ្ទាល់ លុះត្រាតែភាគីម្ខាងទៀតមិនមានភស្តុតាងផ្ទុយ បើគ្មានការបង្ហាញភស្តុតាងទេ ទោះជាខ្ចីយកទៅធ្វើអ្វីក៏ដោយ ក៏ត្រូវចាត់ទុកថាជាបំណុលរួមដែរ ហេតុនេះហើយភស្តុតាងសម្រាប់បញ្ជាក់វាជារឿងដ៏សំខាន់។

### ៣.២.២. អកម្មទ្រព្យរួម

អកម្មទ្រព្យរួម ឬ បំណុលរួម គឺជាបំណុលដែលកើតនៅអំឡុងពេលអាពាហ៍ពិពាហ៍ វាជាកាតព្វកិច្ច រួមរបស់សហព័ទ្ធទាំងសងខាង ដែលបំណុលនោះកើតពីការចំណាយដើម្បីរក្សាជីវភាពរួមរបស់ប្តី ប្រពន្ធចំណាយលើការអប់រំ ឬ ការព្យាបាល ថៃទាំកូន ព្រមទាំងកាតព្វកិច្ច និងករណីកិច្ចផ្សេងៗ ទៀតដែលសហព័ទ្ធទាំងសងខាងបានព្រមព្រៀងជាមួយម្ចាស់បំណុល ឬ កាតព្វកិច្ច និងករណីកិច្ច ផ្សេងៗទៀត ដែលសហព័ទ្ធណាម្ខាង បានទទួលបន្ទុក ដោយមានការយល់ព្រមពីសហព័ទ្ធ ម្ខាងទៀត។ ការព្រមព្រៀងខាងលើ ត្រូវធ្វើជាលិខិតជាលាយល័ក្ខណ៍អក្សរ[77] ដើម្បីជៀសវាងការ ដាក់បន្ទុកធ្ងន់ធ្ងរទៅលើភាគីម្ខាងៗ។

## ផ្នែកទី៤៖ បញ្ហាប្រឈមដែលកើតមាន

## ៤.១. ផុតអាជ្ញាយុកាលនៃបណ្តឹង

នៅក្នុងចំណោម បណ្តឹងទាមទារឲ្យមោឃភាព បណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍និង បណ្តឹងលែងលះ មានតែមូលហេតុមួយចំនួនដែលនាំឲ្យមានការលុបចោលនូវចំណងអាពាហ៍ពិពាហ៍ទេ ដែលមានកំណត់អាជ្ញាយុកាលនៃការប្តឹងទាមទារ ដែលក្នុងនោះមានដូចជា៖ មូលហេតុអាយុ មូលហេតុស្ត្រីស្ថិតក្នុងអំឡុងពេលហាមឃាត់ និង មូលហេតុឆបោក ឬគម្រាម។

[77] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា៩៧៥។

ក្នុងករណីដែលអាជ្ញាយុកាលកំណត់ត្រូវបានហួសអំឡុងពេល នៃការធ្វើបណ្ដឹងដើម្បីទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ ប៉ុន្តែសហព័ទ្ធណាម្ខាងមិនមាន បំណងចង់បន្តនូវចំណងអាពាហ៍ពិពាហ៍ នោះភាគីមិនអាចធ្វើការប្ដឹងទាមទារ ឲ្យលុបចោលអាពាហ៍ពិពាហ៍បានទេ។ ផ្ទុយទៅវិញភាគីមានវិធីម្យ៉ាងទៀតដែលអាចផ្ដាច់ នូវចំណងអាពាហ៍ពិពាហ៍របស់ខ្លួនបានគឺ ធ្វើបណ្ដឹងលែងលះ។

## ៤.២. មរណភាពភាគី

ក្នុងអំឡុងពេលនៃបណ្ដឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ ប្រសិនបើមានភាគីណាម្ខាងទទួលមរណភាព នាំឲ្យបណ្ដឹងទាមទារ ឲ្យលុបចោលនោះត្រូវបញ្ចប់។ ដូច្នេះ ភាគីដែលនៅរស់ នឹងក្លាយទៅជាសន្តតិជនជានិច្ច [78] ដែលអាចស្នងមរតក របស់សហព័ទ្ធដែលបានទទួលមរណភាព ដោយមូលហេតុថាអាពាហ៍ពិពាហ៍ របស់ពួកគេនៅមានសុពលភាពនៅឡើយ។

## ៤.៣. មិនមានភាពទូលំទូលាយក្នុងការអនុវត្តន៍

នៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យ៉ាងច្បាស់អំពីមូលហេតុដែលបណ្ដាលឲ្យមាន បណ្ដឹងទាមទារឲ្យមោឃភាព បណ្ដឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍និងបណ្ដឹងលែងលះ។ តាមដែរយើងសង្កេត គឺឃើញថាការ កើតឡើងនូវបណ្ដឹងទាមទារឲ្យលុបចោលនៅមានចំនួនតិចតួចនៅឡើយ។ ក្នុងដែរយើងអាចមើលឃើញពីបញ្ហាពីរដែលកើតមានឡើងមូលហេតុពីរគឺ៖ ការខ្វះការយល់ដឹងផ្នែកច្បាប់ និង មិនមានការយល់ដឹងផ្នែកច្បាប់។

- ការខ្វះការយល់ដឹងផ្នែកច្បាប់៖ មានន័យថាប្រជាពលរដ្ឋមានការយល់ដឹងមួយចំនួន ផ្នែកច្បាប់ដែល ទាក់ទងនឹងបណ្ដឹងទាមទារទាំងបីខាងលើនេះ ប៉ុន្តែការយល់ដឹងនោះមានចន្លោះខ្វះខាតដែលនាំឲ្យមានការភ្លាំងភ្លាត់ក្នុងដំណើរការនីតិវិធី។

**ឧទាហរណ៍៖** A ត្រូវជាបងប្អូនជីដូនមួយនឹងគ្នា B ថ្ងៃមួយ Aបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងB ដោយសារភាពសមរម្យ រួមជាមួយការផ្សំផ្គុំ ពីសំណាក់ឪពុកម្ដាយ ទាំងសងខាងផងដែរ។ ដោយអ្នកទាំងពីរ ពុំបានដឹងសោះឡើយពីការមិនស្របច្បាប់ នៃអាពាហ៍ពិពាហ៍របស់ខ្លួន។ ថ្ងៃមួយ A មានបានដឹងថា អាពាហ៍ពិពាហ៍របស់ខ្លួនមិនស្របច្បាប់ ហើយភាគី A ក៏បានទៅប្រាប់ ប្រធានភូមិថាគាត់ នឹងលែងលះគ្នាជាមួយនិង B ចាប់ពីពេលនេះតទៅហើយ។

[78] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា១១៦១។

- មិនមានការយល់ដឹងផ្នែកច្បាប់៖ មានន័យថាប្រជាពលរដ្ឋមិនមានការយល់ដឹងទាល់តែសោះទាក់ទងនឹងស្ថានភាពដែលខ្លួនកំពុងជួបប្រទះ ថាអាចនឹងលុបចោលអាពាហ៍ពិពាហ៍របស់ពួកគាត់បាន។

**ឧទាហរណ៍៖** លោក ក ជាអ្នកមានអំណាច គាត់មានបំណងចង់រៀបការជាមួយនារី ខ ប៉ុន្តែនាងមិនព្រម។ ហេតុនេះ គាត់ក៏គម្រាមនាងថានឹងធ្វើឲ្យគ្រួសារនារី ខ បាត់បង់ការងារទាំងអស់បើមិនព្រមរៀបការជាមួយគាត់។ នារី ខ បានយល់ព្រមសំណើសុំរៀបការរបស់លោក ក ទាំងស្ទាក់ស្ទើរ ហើយពួកគេក៏បានរៀបការជាមួយគ្នា។ ករណីនេះ នារី ខ អាចលុបចោលអាពាហ៍ពិពាហ៍បាន តែដោយហេតុថា នាងមិនបានយល់ដឹងចំណុចនេះទាល់តែសោះ នាងក៏បន្តរួមរស់ជាមួយលោក ក ទាំងគ្រាំគ្រាចិត្ត។

## ៤.៤. ការទទួលខុសត្រូវព្រហ្មទណ្ឌ

អាពាហ៍ពិពាហ៍ដែលកើតឡើង ដោយការបំពានមូលហេតុ ដែលនាំឲ្យមានការលុបចោលមួយចំនួនអាចនឹងធ្វើឲ្យភាគី ឈានទៅដល់ការទទួលខុសត្រូវព្រហ្មទណ្ឌ។ មូលហេតុទាំងនោះរួមមាន៖ អាពាហ៍ពិពាហ៍ដែលកើតឡើងដោយការឆបោក និង អាពាហ៍ពិពាហ៍ដែលកើតឡើងដោយការគំរាមកំហែង។

អាពាហ៍ពិពាហ៍ដែលចាត់ទុកថាជាការ ឆបោកគឺ អាពាហ៍ពិពាហ៍ដែលកើតឡើងពីការឆបោករបស់ភាគីម្ខាង ដោយប្រើឈ្មោះក្លែងក្លាយ ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត [79] ក្នុងគោលបំណងឲ្យភាគីម្ខាងទៀងខូចប្រយោជន៍ ឬ ការប្រគល់ពីជនរងគ្រោះនូវ វត្ថុមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។

**ឧទាហរណ៍៖** ភាគីជាប្តីបានកុហកថាខ្លួនជាម្ចាស់ក្រុមហ៊ុនមួយកន្លែងដើម្បីបានរៀបការ ជាមួយប្រពន្ធក្នុងគោលបំណង ឲ្យប្រពន្ធយកប្រាក់មក ដាក់ទុនដើម្បីធ្វើជំនួញរួមគ្នាក្រោយរៀបអាពាហ៍ពិពាហ៍។ ប៉ុន្តែក្រោយមកទើបប្រពន្ធបានដឹងថា ក្រុមហ៊ុនដែលប្តីបានអះអាងនោះ គ្មានរូបរាងពិតប្រាកដ ហើយប្រាក់ដែលប្រគល់ឲ្យប្តីនោះត្រូវបានចាញ់ល្បែងអស់ ព្រមទាំងជំពាក់បំណុលគេទៀតផង។

ក្នុងករណីខាងលើនេះ ក្រៅពីអាពាហ៍ពិពាហ៍អាចរងនូវការលុបចោលហើយ ភាគីខាងប្តីក៏ត្រូវទទួលនូវទោសព្រហ្មទណ្ឌលើ បទឆបោកផងដែរ ដែលទោសដែលត្រូវអនុវត្តនោះគឺ ត្រូវផ្តន្ទា

[79] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិការ ២០០៩, មាត្រា៣៧៧។

ទោសដាក់ពន្ធធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។[80]

ចំណែកឯ អាពាហ៍ពិពាហ៍ដែលចាត់ទុកថា គំរាមកំហែង គឺ ការគំរាមកំហែងក្រោមទម្រង់ណាក៏ដោយថា នឹងប្រព្រឹត្តបទឧក្រិដ្ឋ បទមជ្ឈិមប្រឆាំងនឹងបុគ្គល ប្រសិនបើការគំរាមកំហែងនេះត្រូវបានធ្វើឡើងដោយមានបញ្ជាឲ្យបំពេញលក្ខខណ្ឌអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និង ពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល។[81]

**ឧទាហរណ៍៖** លោក ក ជាអ្នកមានអំណាចបានគំរាមនារី ខ ថានឹងធ្វើទារុណកម្មលើ គ្រួសារនាងបើនាងមិនព្រមរៀបការជាមួយគាត់ទេ។ ដោយខ្លាចអំណាចរបស់ លោក ក នារី ខ ក៏យល់ព្រមរៀបការជាមួយលោក ក ទាំងភ័យខ្លាច។

---

[80] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិការ ២០០៩, មាត្រា៣៧៨។

81 [81] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិការ ២០០៩, មាត្រា២៣២។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវទាក់ទងនឹងប្រធានបទ "**ការលុបចោលអាពាហ៍ពិពាហ៍**" នេះមកយើងសង្កេតឃើញថា ទោះជាមានភាពខុសគ្នារវាងមូលហេតុដែលនាំឲ្យកើតមាននូវបណ្តឹងទាមទាឲ្យមោឃភាពបណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ និង បណ្តឹងលែងលះយ៉ាងណាក្តី ប៉ុន្តែក៏មានចំណុច ប្រសព្វរួមនូវលទ្ធផលនៃការផ្តាច់ចំណងគតិយុត្តរវាង សហព័ទ្ធទាំងនពីរដូចគ្នាគឺ ធ្វើឲ្យជីវិតគ្រួសារ ដែលធ្លាប់តែរួមរស់ជាមួយគ្នាប្រែក្លាយជាអ្នកដទៃ ។ ការចែកផ្លូវគ្នារវាង អ្នកទាំងពីរមិនត្រឹមតែជះ ឥទ្ធិពលចំពោះខ្លួនគេប៉ុណ្ណោះទេ តែក៏អាចប៉ះពាល់ដល់អារម្មណ៍កូនដែលធ្លាប់តែរស់នៅជាមួយ នឹងឪពុកម្តាយ បែរជាត្រូវឈរមើលពួកលោកទាំងពីរបែកគ្នាជាងនេះទៅទៀតនោះគឺ ត្រូវជ្រើសរើសឬ បាត់បង់ ម្នាក់ក្នុងចំណោមអ្នកមានគុណទាំងពីរតាមសេចក្តីសម្រេចរបស់តុលាការ។ មិនតែប៉ុណ្ណោះ រវាងសមាជិកគ្រួសារទាំងពីរ អាចនឹងមើលមុខគ្នាមិនចំ ពោលគឺបាត់បង់ទាំងភាព ជាសាច់ញាតិនឹងគ្នា និង មិត្តភាព ហើយអាចនឹងឈានដល់ស្ថានភាពដែលក្លាយជាសត្រូវនឹងគ្នាក៏មាន។ លើសពីនេះ ការបែងចែកទ្រព្យសម្បត្តិក៏នឹងក្លាយជាបញ្ហាដែលនាំឲ្យមានការថ្នាំងថ្នាក់ នៅពេលដែលមិនមានការព្រមព្រៀងមួយជាក់លាក់ ដែលអាចនឹងក្លាយទៅជាជម្លោះផងដែរ។

ជាភ័ព្វសំណាងដែលប្រទេសកម្ពុជាមាននូវច្បាប់មួយចំនួនដូចជា ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ជាដើម។ ដែលក្នុងនោះមានបញ្ញត្តិអំពី មូលហេតុដែលអាចនិយាយបានថាជាវិធាននៃការការពារ មិនឲ្យមានបណ្តឹងលុបចោលអាពាហ៍ពិពាហ៍នេះកើតឡើង។ ក៏ប៉ុន្តែបើបញ្ញត្តិជាមូលហេតុខាងលើត្រូវបានគេបំពាននោះក៏មានបញ្ញត្តិបន្តដែលជានីតិវិធី ឬ ដំណោះស្រាយបញ្ហាដែលកើតមានជាបន្តបន្ទាប់ផងដែរដូចជា ការផ្តាច់ចំណងគត្តិយុត្ត បញ្ហាបុត្តភាព និង ទ្រព្យសម្បត្តិដែលត្រូវធ្វើការដោះស្រាយក្រោយមានការបែកបាក់រវាងអ្នកទាំងពីរ។

ទោះជាយ៉ាងណា គ្មានអ្វីដែលល្អឥតខ្ចោះនៅលើលោកនេះទេ ដូចគ្នាទៅនឹងច្បាប់នីមួយៗផងដែរ គឺតែងមានចន្លោះខ្វះខាត ដែលនាំឲ្យមានភាពស្មុគស្មាញ ដល់តុលាការក្នុងការដោះស្រាយរឿងក្តី ក៏ដូចជាខ្វះខាតនូវធនធានមនុស្សក្នុងវិស័យច្បាប់ ដែលអាចជាមូលហេតុមួយនាំឲ្យមានការយឺតយ៉ាវក្នុងដំណើរការបណ្តឹង។ ហេតុនេះ សិស្សនិស្សិត ក៏ដូចជាប្រជាពលរដ្ឋគប្បីសិក្សាយល់ដឹងនូវបញ្ញត្តិច្បាប់ឲ្យបានច្រើន ដែលអាចការពារខ្លួន អ្នកដទៃ ក៏ដូចជាសង្គមឲ្យជៀសផុតពីភាពវឹកវរដែលកើតពីការប្រព្រឹត្តផ្ទុយនឹងច្បាប់ប្រទេស មិនតែប៉ុណ្ណោះក៏អាចជួយឲ្យប្រទេសរីកចម្រើនមួយកម្រិតផងដែរ។

# អនុសាសន៍

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវកន្លងមក បានបង្ហាញឃើញថាការកើតមានឡើងនៃបណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ និង បណ្តឹងទាមទាឲ្យមោឃភាព នៅមានចំនួនតិចតួចនៅឡើយបើធៀបទៅនឹងបណ្តឹងលែងលះ។ បើទោះជាមានភាពខុសគ្នាទៅលើចំណុចមួយចំនួនក្នុងដំណើរការនីតិវិធីរវាងបណ្តឹង ទាំងពីរខាងលើក៏ដោយ តែអានុភាពនៃបណ្តឹងទាំងនេះមានគោលដៅនិងលទ្ធផលដូចគ្នា។ ដូចដែលយើងខ្ញុំបានបកស្រាយយ៉ាងលម្អិតក្នុងចំណុច នីមួយៗខាងលើ ពោលគឺ មានការបែកបាក់ គ្រួសារឪពុកម្តាយនិងកូន ព្រមទាំងមានការបែងចែកនូវទ្រព្យសម្បត្តិផងដែរ។ មិនតែប៉ុណ្ណោះ អាចធ្វើឲ្យខាតបង់ពេលវេលា និងថវិកាទៀតផង។

ការកើតឡើងនៃបណ្តឹងទាមទារឲ្យមោឃភាពបណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍មានចំនួនមិនច្រើន មិនមានន័យ ថាករណីបំពានមូលហេតុដែលនាំឲ្យមានការមោឃភាព ឬការលុបចោលអាពាហ៍ពិពាហ៍មិនកើតមានឡើងទេ។ ក្នុងសង្គមជាក់ស្តែងការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋមានកម្រិតនៅឡើយ ជាហេតុដែលនាំឲ្យ ប្រជាពលរដ្ឋទាំងនោះមិនបានដឹងថាករណីដែលពួកគេបាននិងកំពុងជួបប្រទះនេះ ជាមូលហេតុ មួយក្នុងចំណោមលក្ខខណ្ឌដែលអាចប្តឹងលុបចោលអាពាហ៍ពិពាហ៍បាន។ ដើម្បីចៀសវាងបញ្ហា ដែលកើតឡើង មុនពេលរៀបអាពាហ៍អនាគតគូស្វាមីភរិយា គប្បីសិក្សាអំពីលក្ខខណ្ឌឲ្យបាន ច្បាស់លាស់ ដែលវាមិនត្រឹមតែចៀសផុតពីបញ្ហាដែលបានរៀបរាប់ខាងលើនោះទេថែមទាំងជួយ សម្រាលបន្ទុក និង ភាពស្មុគស្មាញដល់តុលាការផងដែរ។

លើសពីនេះ ការយល់ដឹងនូវច្បាប់របស់ប្រទេសមិនត្រឹមតែ អាចជួយខ្លួនឯងប៉ុណ្ណោះទេតែក៏អាចជាផ្នែកមួយដែលជួយអភិវឌ្ឍសង្គមជាតិឲ្យរីកចម្រើនផងដែរ។ ហេតុនេះមិនថាសិស្សនិស្សិត ប្រជាពលរដ្ឋ គប្បីសិក្សាស្វែងយល់បន្ថែមទៅលើផ្នែកច្បាប់នានា ឲ្យបានច្បាស់លាស់ដើម្បីជាសសរទ្រូងរបស់ប្រទេស។ ស្របពេលជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលគប្បីធ្វើការផ្សព្វផ្សាយបន្ថែមទៅលើផ្នែកច្បាប់តាមបណ្តាញសង្គម ឬប្រព័ន្ធផ្សេងៗ ដូចជា ទូរស្សន៍ វិទ្យុ កាសែតទស្សនាវត្តី ឬបណ្តាញសង្គមហ្វេសប៊ុក (facebook), តេឡេក្រាម (telegram) ឬចាត់តាំងមន្ត្រីដែលមានជំនាញទៅបង្រៀនដល់មូលដ្ឋានដាច់ស្រយាល ដែលពួកគេទាំងនោះខ្វះខាតការយល់ដឹង និងដើម្បីជាជំនួយដល់ប្រជាពលរដ្ឋ ដែលមិនឱកាសបានរៀនសូត្រ ឲ្យពួកគាត់បានយល់ដឹងបន្ថែមដើម្បីជាកម្លាំងមួយផ្នែកទៀត ក្នុងការអភិវឌ្ឍន៍ប្រទេស និងផ្តល់សន្តិភាពជូនជាតិ។

# ឯកសារយោង


- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា,២៤ កញ្ញា ឆ្នាំ១៩៩៣។

- ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦។

- ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧។

- ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩។

- ច្បាប់ស្តីពី ឯកពន្ធភាព,លេខ នស/រកម/១០០៦/០២៦,០១ កញ្ញា ២០០៦។

- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី,លេខ នស/រកម/១០៩៦/៣០,៩ តុលា ឆ្នាំ១៩៩៦។

- ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល,លេខ នស/រកម/០៦១០/០០៨,៨ មិថុនា ២០១០។

- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ,លេខ៥៦ក្រ,២០ កក្កដា ឆ្នាំ១៩៨៩។

- អនុក្រឹត្យស្តីពី អគ្រានុកូលដ្ឋាន,លេខ១០៣ អនក្រ.បក,២៩ ធ្នូ ឆ្នាំ២០០០។

-អនុក្រឹត្យស្តីពីការកំណត់បែបបទនិងនីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងជនបរទេស, លេខ១៦៨ អនក្រ.បក,១២ ខែវិច្ឆិកា ឆ្នាំ២០០៨។

- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៥. គន្ថីទី៧, ឆ្នាំ២០១០។

- វចនានុក្រម សម្តេច ព្រះសង្ឃរាជ ជួន ណាត។

- សន្ទានុក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

-ស្រី វណ្ណធី. ២០១៨. នីតិបេតិកភណ្ឌ និងគ្រួសារ។

-ស្រី វណ្ណធី. ២០១៦. នីតិរដ្ឋប្បវេណី, បោះពុម្ពលើកទី២។

-សិក្ខាសាលាគណៈមេធាវី(ធំ)លើកទី៧,ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៤។

-សិក្ខាសាលាស្តីអំពីមោឃភាព និងការលុបចោល, អ៊ីវ ប៉ូលី, ២០១៨។